# ទស្សនវិជ្ជា
# ពុទ្ធសាសនា

ព្រះមហាវីរិយ បណ្ឌិតោ

## ច៉ាង ខាត់

### រៀបរៀង

[ទស្សនាវដ្ដីកម្ពុជសុរិយា: លេខ៨, ៩, ១០, ១១ ឆ្នាំ១៩៦៩ ]

អ្នកផងទូទៅតែងនិយាយថា ៖ ពុទ្ធសាសនា ជាលទ្ធិសាសនា (Religion); ពាក្យថា Religion នេះ មិនគួរយកទៅប្រើសម្រាប់ហៅ ពុទ្ធសាសនាទេ ព្រោះពុទ្ធសាសនា ជាផ្លូវប្រតិបត្តិមិនទាក់ទងទៅខាងលទ្ធិ ទិដ្ឋិ (Dogme), វាទ (Doctrine) ដូចលទ្ធិសាសនា (Religion) ដទៃៗនោះឡើយ។ ក្នុងគម្ពីរពុទ្ធសាសនាមានពាក្យចោទឆ្លើយថា ៖ សាសនាមានប៉ុន្មាន?

ឆ្លើយថាមាន ២យ៉ាងគឺ ១- ពុទ្ធសាសនា ២- ពាហិរសាសនា។ សាសនាទីពីរ គឺពាហិរសាសនា (Religion) សំដៅយកលទ្ធិសាសនាទាំងអស់ក្រៅពីពុទ្ធសាសនា ព្រោះសុទ្ធតែជាលទ្ធិ (Dogme) វាទ (Doctrine)។ល។ ឯពុទ្ធសាសនាជាបដិបទាផ្លូវប្រតិបត្តិជាកម្មនិយម ឬជាវិធីបំបាត់អវិជ្ជា តណ្ហា ឧបាទានកម្ម។ សេចក្ដីពិត អង្គព្រះសម្ពុទ្ធមិនមែនជាអ្នកបង្កើតពុទ្ធសាសនាទេ ព្រះអង្គគ្រាន់តែជាអ្នកឃើញធម៌ ហើយប្រកាសធម៌ដែលទ្រង់ត្រាស់ដឹងនោះ។ ទ្រង់មិនដែលប្រកាសព្រះអង្គថាជាអ្វីដទៃ ក្រៅពីព្រះអង្គជាមនុស្សឡើយ ពោលគឺទ្រង់ជាមនុស្សសុទ្ធសាធ។ មេសាសនាដទៃច្រើនតែលើកខ្លួនថាជាទេពតា ជាអាទិទេពនៅឋានសួគ៌ ឬជាអវតារនៃអាទិទេព ក្នុងការបែងភាគទៅជារូបផ្សេងៗ។ ព្រះអង្គជាមនុស្សហើយទ្រង់មិនដែលប្រកាសថា ព្រះអង្គមានអ្នកណា ឬទេពតាណា មានសក្ដានុភាពចូលមកណែនាំព្រះអង្គឲ្យប្រកាសសាសនា ដូចសាសនាទាំងពួងទេ។ ផលប្រសើរដែលទ្រង់បានសម្រេចអភិសម័យគឺការលុះធម៌ ការត្រាស់ដឹងធម៌ មិនមែនបានដោយឫទ្ធិអំណាចទេពតា ជួយផ្ដល់ឲ្យបានសម្រេចទេ គឺទ្រង់បានសម្រេចដោយវិរិយភាពព្រះអង្គជាមនុស្ស ដោយបញ្ញាញាណព្រះអង្គជាមនុស្សពិតប្រាកដ។ មនុស្សយើង បើគ្រាន់តែបានភាពជាមនុស្សប៉ុណ្ណឹង អាចលុះភាពនៃខ្លួនជា "ពុទ្ធ" បានឥតសង្ស័យឡើយ។ មនុស្សរាល់រូបអាចប្រើសក្ដានុភាពខ្លួន ជាមនុស្សឲ្យបានសម្រេចភាពជាព្រះពុទ្ធបាន ថាបើមានបំណងមាំនិងមានវិរិយភាពធំ។ ដូច្នេះ យើងអាចពោលបានថា អង្គព្រះសម្ពុទ្ធជាមនុស្សដោយប្រពៃមិនខុសទាស់អ្វីទេ ព្រោះព្រះអង្គខំបំពេញបារមីធម៌ក្នុងមនុស្សភាព មិនមែនក្នុងទេវតាភាពឡើយ ហើយទ្រង់បានសម្រេចភាពជាមហាបុរសរតន៍ឆ្នើមបំផុត ក្នុងចំណោមមនុស្សជាមេសាសនាធំៗ ក្នុងពិភពលោក ទាល់តែមនុស្សលោកពិលក្នែកមើលព្រះអង្គ ឃើញព្រះអង្គ ហើយសំគាល់ថា ទ្រង់ជាឧត្ដរមនុស្ស (Super humain)។

ការបានភាពនៃខ្លួនជាមនុស្សប្រសើរបំផុត (កិច្ឆោ មនុស្ស បដិលាភោ)។ មនុស្សជាម្ចាស់ខ្លួនឯង ឥតមានទេពតាណា ឬអំណាចអ្វីណាមួយប្រសើរជាងវាលនាខ្លួនជាមនុស្សនេះទេ។ មនុស្សម្នាក់ៗ ជាកោះទីពឹងរបស់ខ្លួន អត្តទីបោ = អ្នកណាជាសរណៈខ្លួនឯង ជាងខ្លួនឯង? ព្រះសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា "ខ្លួនជាទីពឹងខ្លួន" មនុស្សម្នាក់ៗមិនត្រូវដើរទៅស្វែងរកសរណៈដទៃក្រៅពីខ្លួនទេ។ កាលទ្រង់គង់ធម៌នៅឡើយ ព្រះសម្ពុទ្ធទ្រង់តែងទេសនាប្រៀនប្រដៅថា ៖ ត្រូវកសាងខ្លួនដោយខ្លួនឯង (អត្តសម្មាបណិធិ) ហើយយកអានុភាពខ្លួនឯងទៅរំដោះទុក្ខ (មោក្ខ) ខ្លួនឯង ឲ្យរួចស្រឡះពីចំណងតណ្ហា ដោយវីរិយភាព និងបញ្ញាជារបស់ខ្លួនឯងជាមនុស្ស។ ទ្រង់ផ្តាំទុកទីបំផុតថា ៖ [១] ចូលធ្វើប្រយោជន៍ខ្លួនឲ្យសម្រេចដោយក្តីមិនប្រមាទ (អប្បមាទេន សម្បាទេថ) ឯពាក្យដែលអ្នកផងតែងពោលថា "ព្រះអង្គស្រង់សត្វ" នោះ គ្រាន់តែជាពាក្យពោលដោយន័យថា ព្រះអង្គត្រាស់ដឹងធម៌ ទេសនាចង្អុលប្រាប់ផ្លូវឲ្យសត្វដើរ គឺប្រៀនប្រដៅសត្វលោកឲ្យខំរៀនឲ្យចេះដឹង ហើយឲ្យដើរដោយខ្លួនឯង ព្រមទាំងធ្វើបានលុះមោក្សធម៌ដោយខ្លួនឯងតែប៉ុណ្ណោះទេ ដោយពិទ យើងត្រូវដើរដោយខ្លួនយើងគ្រប់គ្នា នឹងឲ្យព្រះអង្គស្រង់យើងដូចស្រង់មនុស្សលង់ទឹកដូចម្តេចបាន? តែមនុស្សលោកចូលចិត្តឲ្យគេស្រង់ខ្លួនទាំងស្រកាកដូចស្រង់មនុស្សលង់ទឹកកណ្តាលទន្លេដូច្នោះឯង។

តាមគោលការណ៍ មនុស្សម្នាក់ៗ ត្រូវទទួលខុសត្រូវដោយខ្លួនឯង។ សេចក្តីត្រង់នេះ ក្នុងពុទ្ធសាសនា ឃើញមានច្រើនកន្លែងណាស់ ទ្រង់តែងតែប្រទានសេរីភាពដល់សាវកព្រះអង្គ។ ក្នុងមហាបរិនិព្វានសូត្រ ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរថា [១] : ។

- អានន្ទ! ភិក្ខុសង្ឃ ត្រូវការអ្វីចំពោះតថាគតទៀត = (កឹ បនានន្ទភិក្ខុសង្ឃោ មយិ បច្ចាសីសតិ)។

អានន្ទ ធម៌ដែលតថាគតសំដែងប្រាប់ហើយ មិនមានក្នុង មិនមានក្រៅទេ បានសេចក្តីថា ធម៌វិន័យនេះ មិនមែនជាអន្តោកូតវាទ (Doctrine ésotérique)

---

១ - មហាបរិនិព្វានសូត្រ ។

១ - ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ សៀវភៅទី១៦ ទំព័រ២ ៣។

មានអ្វីលាក់លៀមទុកក្រោយទៀតទេ = (នេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ)។

“**អានន្ទ ! អាចរយមុដ្ឋិ** ក្នុងធម៌តថាគតមិនមានទេ បានសេចក្តីថា ធម៌វិន័យនេះ មិនមែនបិតនៅក្នុងកណ្តាប់ដៃអាចារ្យ គឺមិនមែនជា (Dogme) របស់អាចារ្យ និយាយក្រៅពីអាចារ្យមិនបាននោះទេ ឧត្តានន្ទ តថាគតស្ស ធម្មេសុ អាចរិយមុដ្ឋិ។

*សេចក្តីតទៅ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទៀតថា ៖*

*អានន្ទ ! តថាគត មិនដែលបានគិតថា មិនត្រូវត្រួតត្រាសង្ឃមណ្ឌល... ឬក៏សង្ឃមណ្ឌលត្រូវនៅក្រោមឱវាទតថាគតដូច្នេះក៏ទេដែរ ឥឡូវនេះ តថាគត គ្រាំគ្រាហើយ ចម្រើនហើយ ចាស់ហើយ កន្លងបច្ឆិមវ័យហើយ មានអាយុ ៨០ឆ្នាំហើយ។*

*សេរីភាពក្នុងការគិត ដែលព្រះអង្គទ្រង់ប្រទានដល់សាវកព្រះអង្គនេះ មិនដែលឮថាមានប្រាកដនៅក្នុងប្រវត្តិសាសនា នៃសកលលោកសោះឡើយ។ សេរីភាពក្នុងការគិតនេះ មានប្រយោជន៍ណាស់ ព្រោះថា អត្តាធិនភាព* (Emancipation) *នៃមនុស្សលោក បិតនៅក្នុងអភិសម័យ* (Réalisation) *អរិយសច្ចធម៌ មិនមែននៅក្រោមការប្រោសប្រាណនៃព្រះអាទិទេព ឬអំណាចនៃបុគ្គលណាមួយសោះឡើយ។ សេចក្តីនេះ បើយើងមើលក្នុងគម្ពីរ ដែលជាពុទ្ធវចនៈ នឹងឃើញមានច្រើនអនេ្ទើណាស់។*

*ក្នុងសម័យមួយ កាលព្រះសម្ពុទ្ធស្តេចយាងទៅកាន់ចារិកក្នុងក្រុងកេសបុត្ត ក្នុងដែនកោសល មានប្រជាជនកាលាមៈ*[១] *ច្រើននាក់បានចូលមកក្រាបទូលសួរព្រះអង្គថា ៈ*

*សូមទ្រង់មេត្តាប្រោស ពួកតាបសឫសី ពួកព្រាហ្មណ៍ច្រើននាក់ដែលបានចូលមកកាន់ក្រុងកេសបុត្តនេះ តែងតែទេសនា អួតសរសើរ លើកតម្កើងវាទៈ របស់ខ្លួនសឹងតែរាល់គ្នា ហើយបន្តុះបង្អាប់វាទនៃសាស្តាដទៃៗ ថាមិនត្រឹមត្រូវ។ យើងខ្ញុំព្រះអង្គគ្រប់គ្នាមានសេចក្តីសង្ស័យមានក្តីធ្ងល់ថា តើបណ្តាពួកតាបសឫសី ពួកព្រាហ្មណ៍ទាំងនោះពួកណានិយាយត្រូវ ពួកណានិយាយខុស។*

---

១ - មើលកាលាមសូត្រ សេចក្តីប្រែព្រះតេជគុណ ព្រះមហាវិមលធម្ម ថោង ពុទ្ធសាសនបណ្ឌិត្យ។ អង្គុត្តរនិកាយ តិក្កនិបាត មហាវគ្គ សៀវភៅទី៤១ ទំព័រ២១៦។

កាលនោះព្រះសម្ពុទ្ធទ្រង់ប្រទានធម៌ទេសនា ដោយអនេកបរិយាយ ទ្រង់វិសជ្ជនា ដោះស្រាយប្រស្នានេះ ដោយពិស្តារ។ សេចក្តីដោះស្រាយបែបនេះ មានតែក្នុងពុទ្ធសាសនាមួយទេ មិនដែលមានប្រាកដនៅក្នុងប្រវត្តិសាសនាសកលលោកឡើយ ដូចសេចក្តីដែលព្រះអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ ដូចតទៅនេះ ៖

" ហៃកាលាមៈ ! អ្នកគួរមានក្តីសង្ស័យមែន អ្នកគួរកើតក្តីឆ្ងល់មែនចំពោះប្រស្នាសង្ស័យដែលគួរឲ្យសង្ស័យនេះ ឥឡូវ ចូរប្រុងស្តាប់ដោយគោរពចុះ អ្នកទាំងឡាយកុំប្រព្រឹត្តអាការ ១០ យ៉ាងគឺ ៖

១. អនុស្សវា ការប្រកាន់ជឿ ដោយអាងពាក្យដែលឮតៗគ្នា គឺមិនបានពិនិត្យពិចារណារកហេតុផល ដោយចេះតែជឿតាមៗគ្នា។

២. បរម្បរា ការប្រកាន់ជឿ ដោយអាងធ្វើតៗគ្នា មិនដឹងដើម មិនដឹងចុង ដូចជាកាន់ទំនៀមទម្លាប់ជាដើម។

៣. ឥតិកិរា ការប្រកាន់ជឿ ដោយអាងថាបានឮមក ឬការប្រកាន់ជឿដោយអាងថា បានឮគេនិយាយមកយ៉ាងនេះ ដូចជាការប្រកាន់ជឿរឿងព្រេងជាដើម។

៤. បិដកសម្បទា ការប្រកាន់ជឿ ដោយអាងថាពាក្យនេះសមនិងគម្ពីរដីកាយើងហើយ គឺអាងក្បួនតម្រាដូចគម្ពីរវេទជាដើម,

៥. តក្កហេតុ ការប្រកាន់ជឿ ដោយអាងហេតុ ឬអនុមាណដោយស្មានយកខ្លួនឯងឃើញយ៉ាងណា ក៏កាន់យកយ៉ាងនេះ,

៦. នយហេតុ ការប្រកាន់ជឿ ដោយអាងន័យគ្នេរគ្នាន់កាត់តម្រួយផ្សេផ្សំយក សំគាល់យកសេចក្តីណាមួយដែលមានន័យប្រហែលគ្នាមកប្រកបហើយប្រកាន់ជឿតាមគ្នា,

៧. អាការបរិវិតក្កា ការប្រកាន់ជឿ ដោយអាងការត្រិះរិះនូវអាការៈគឺហេតុអ្វីដែលកើតឡើង តែមិនមែនជាការពិត ត្រិះរិះផ្គួផ្គងមើលទៅឃើញថា ពេញចិត្តខ្លួនយល់ថា ត្រឹមត្រូវហើយក៏ប្រព្រឹត្តកាន់តាមទៅ,

៨. ទិដ្ឋិនិជ្ឈានក្ខន្តិ ការប្រកាន់ជឿ ដោយអាងការចូលចិត្តគឺហេតុអ្វីមួយដែលមិនមែនជាការពិត តែត្រូវនឹងគំនិតដែលខ្លួនធ្លាប់គិតទុកមក ចូលចិត្តថាហេតុនោះល្អហើយ ពិតហើយ ក៏ប្រព្រឹត្តតាមហេតុការណ៍នោះ។

៩. ភព្វរូបតា ការប្រកាន់ជឿដោយអាងថា អ្នកនេះជាអ្នកចេះដឹង គួរតែយើងជឿកាន់តាម បានសេចក្តីថា អ្នកណាមួយប្រសប់ប៉ិនប្រសប់ខាងសម្តីថ្វីមាត់តែងពាក្យអ្នកនិយាយនេះមិនពិតទេ គ្រាន់តែពីរោះស្តាប់ ហើយប្រកាន់ជឿតាមអ្នកនោះទៅ។

១០. សមណោ នោគរុ ការប្រកាន់ជឿដោយអាងថា សមណៈនេះជាគ្រូយើង គួរយើងកាន់យកតាម ពាក្យលោក គឺការប្រកាន់ជឿតាមលទ្ធិគ្រូខ្លួន បើទុកជាលទ្ធិគ្រូខ្លួនខុសក៏ដោយ ក៏ចេះតែប្រកាន់ជឿតាមទាំងអស់ វាទទៈ អ្នកដទៃដែលមិនមែនជាគ្រូខ្លួន តែត្រឹមត្រូវមិនប្រកាន់ជឿតាមទេ។

នៃកាលាមៈ ! អ្វីមួយដែលអ្នកបានឃើញខ្លួនឯងថា នេះជាកុសលជារបស់ប្រសើរ អ្នកចូរប្រព្រឹត្តតាមចុះ ! អ្វីមួយដែលអ្នកបានឃើញខ្លួនឯងថា ជាអកុសលជាធម៌លាមក ខុសគន្លងធម៌ អ្នកគួរលះបង់ចោលទៅ កុំប្រព្រឹត្តតាមឡើយ។

សាវកព្រះពុទ្ធ វៀរអាការ ១០យ៉ាងនេះ លោកប្រើសទ្ធា និងបញ្ញាពិចារណារកហេតុផលទើបជឿកាន់តាម ប្រតិបត្តិតាម។

ក្នុងគម្ពីរដែលជាពុទ្ធវចនៈមានសេចក្តីដាស់តឿន ឲ្យសាវកព្រះអង្គចេះគិតប្រើគំនិតគឺការប្រទានសេរីភាព ក្នុងការគិតមានច្រើនអន្លើណាស់ ដូចព្រះតម្រាស់ចំពោះភិក្ខុទាំងឡាយ ថា[១] ភិក្ខុទាំងឡាយ សាវក តថាគត ត្រូវពិនិត្យមើលពាក្យតថាគត សាវកតថាគតត្រូវច្បាំងចំពោះសច្ចធម៌តថាគតដែលជាគ្រូឲ្យឃើញត្រឹមត្រូវសិន សឹមប្រតិបត្តិតាម ដូចជាយើងនិយាយថា "ឲ្យឃើញសឃើញខ្មៅ" សិន។

ក្នុងពុទ្ធសាសនា **វិចិកិច្ឆា** សេចក្តីសង្ស័យ (Doute, Doubt) នេះជាធម៌មួយ នៅក្នុង

១ - មជ្ឈិមនិកាយ មូលបណ្ណាសក វិមំសកសូត្រ សៀវភៅទី២២ ទំព័រ ៣៣៧។

នីវរណធម៌ [២] (Empêchements, Hindrances) ទាំង ៥ ប្រការ ជាធម៌រាំងបិទមិនឲ្យយល់អរិយសច្ចធម៌ ឬ មិនឲ្យកើតសេចក្ដីចម្រើនគ្រប់ប្រការ។ តែ **វិចិកិច្ឆា** នេះ មិនមែនជាអំពើបាបកម្មទេ ព្រោះថាមិនមានដែលត្រូវប្រើជំនឿ មិនមានអំពើបាបកម្ម (Péchésin) ដូចនៅក្នុងលទ្ធិសាសនា (Religion) ដទៃៗទេ។ ឯមូលៈ (Racine, Root) ឬ ឫសគល់នៃបាបកម្មនោះ គឺអវិជ្ជា (Ignorance) និង **មិច្ឆា** (Vues fausses, False views)។ នេះជាធម៌ដែលគេប្រកែកជជែកមិនបាន បើមាន **វិចិកិច្ឆា** មានការងឿងឆ្ងល់ មានសន្ទិះសង្ស័យហើយសេចក្ដីចម្រើនពិតជាមិនអាចកើតឡើងបានទេ។ មួយទៀត ធម៌នេះក៏គេប្រកែកជជែកមិនបានដែរថា គេមិនត្រូវទុក**វិចិកិច្ឆា** នេះ ឲ្យនៅយូរលង់ទេ បើគេមិនយល់ ឬ បើគេមិនឃើញច្បាស់។ បើគេចង់ឲ្យសេចក្ដីចម្រើនដើរលឿនទៅមុខ ត្រូវតែបំបាត់**វិចិកិច្ឆា**នេះចោលបង់ឲ្យស្រឡះ តែដើម្បីនឹងបំបាត់**វិចិកិច្ឆា** ក៏ត្រូវតែគេឃើញច្បាស់សិនដែរ។

តែសេចក្ដីនេះ មិនមែនត្រូវយល់ថា គេមិនត្រូវឲ្យមានក្ដីសង្ស័យ ឬ មិនត្រូវឲ្យមានជំនឿនោះទេ បើគ្រាន់តែនិយាយថា "ខ្ញុំជឿ" ក៏មិនមែនបានសេចក្ដីថា "យល់ ឬ ឃើញ " នោះទេ។ សេចក្ដីនេះ ប្រៀបដូចជាសិស្សគណិតសាស្ត្រ ដែលគិតចំណោទគណិតសាស្ត្រ ជួនកាលខ្លះតែងមានចំណុចមួយ ដែលសិស្សនេះមិនដឹងធ្វើដូចម្ដេចនឹងឲ្យទៅមុខរួច ឬ ខ្លួនលង់ទ្រនេសនៅក្នុង **វិចិកិច្ឆា** ឬ ក្នុងការងឿងឆ្ងល់ដែរ។ ដរាបណាសិស្សនេះ នៅតែមាន**វិចិកិច្ឆា** ដរាបនោះ សិស្សនេះនៅតែធ្វើទៅមុខមិនបានទេ។ បើសិស្សនេះ ចង់ធ្វើឲ្យទៅមុខរួច លុះត្រាតែសិស្សនេះដោះ**វិចិកិច្ឆា**នេះបានសិន ទើបទៅមុខបាន។ ក្នុងករណីនេះ មានមធ្យោបាយអាចជួយឲ្យសម្រេចបានដែរឬទេ? បើគ្រាន់តែនិយាយថា "ខ្ញុំជឿ" ឬ "ខ្ញុំមិនសង្ស័យទេ" នេះទៀត ក៏មិនអាចដោះស្រាយចំណោទបានពិតប្រាកដទៀត បើទុកជាបង្ខំជឿអ្វីមួយ ហើយព្រមទទួលយកអ្វីមួយនោះ ដោយ

---

២ - នីវរណធម៌ (Empêchements, Hindrances) ៥ ប្រការ គឺ :

១- កាមឆន្ទ (La convoitise sensuelle, Sensua Lust); ២- ព្យាបាទ (La malveillance, III-will); ៣- ថីនមិទ្ធ (La torpeur physique et mentale et la langueur, physical and mental torpor and langueur); ៤- ឧទ្ធច្ច កុក្កុច្ច (L'inquiétude et le tracas, Restlessness and worry); ៥-វិចិកិច្ឆា (La donte, Doubt)។

ឥតបានយល់សោះ នេះអាចទៅបានដែរ បានខាងវិស័យការរដ្ឋ តែនិងទុកជាបានការខាងវិស័យធម្មៈ ឬ ខាងវិស័យចំណេះដែលមានហេតុផលពុំបានឡើយ។

ព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាប្រដៅជានិច្ចថា ត្រូវបំបាត់ **វិចិកិច្ឆា** ចោលឲ្យស្រឡះបង់ ពេលមុនបរិនិព្វាន ព្រះអង្គត្រាស់ហើយត្រាស់ទៀត ឲ្យព្រះសង្ឃសាវកសាកសួរព្រះអង្គ កុំឲ្យទុក **វិចិកិច្ឆា** នេះ ចំពោះធម្មវិន័យព្រះអង្គ ដើម្បីកុំឲ្យកើតវិប្បដិសារធម៌ទៅថ្ងៃក្រោយ ហើយមិនអាចកំចាត់**វិចិកិច្ឆា** នេះបាន។ តែកាលនោះ ព្រះសង្ឃសាវកតាំងនៅក្នុងតុណ្ហីភាពគ្រប់អង្គ ទើបទ្រង់ត្រាស់ទៀតថា [១] ៖ ។

ភិក្ខុទាំងឡាយ ! បើអ្នកទាំងឡាយ មានគរុគារវធម៌ មិនអាចហ៊ានលើកប្រស្នាឡើងសួរទេ ឲ្យសទ្ធិវិហារិកណាម្នាក់ចូលមកសួរតថាគតចុះ កុំទុកឲ្យមាន**វិចិកិច្ឆា** នេះ តទៅទៀត។

សេចក្តីខាងលើនេះ អ្នកសិក្សាប្រវត្តិសាស្ត្រលទ្ធិសាសនាកោតស្ញើចក្រៃលែងចំពោះអង្គព្រះសម្ពុទ្ធ ដែលទ្រង់មានព្រះហឫទ័យទូលាយ ទ្រង់មិនមែនព្រះរាជទានត្រឹមតែសេរីភាពក្នុងការគិតតែប៉ុណ្ណោះទេ ទ្រង់ប្រកបដោយក្តីខន្តីធម៌ មេត្តាប្រោសសន្តោសព្រះសង្ឃសាវកទៀតផង។ សម័យមួយ នៅស្រុកនាលន្ទា **និគណ្ឋនាដបុត្ត** ដែលយើងបានស្គាល់ថា **តិដ្ឋង្ករមហាវីរ** បានបញ្ជូនសិស្សជំនិតម្នាក់ ជាគហបតី មានទ្រព្យសម្បត្តិស្តុកស្តម្ភ ឈ្មោះឧបាលិ [១] ឲ្យទៅគាល់អង្គព្រះសម្ពុទ្ធ ដើម្បីដេញដោលសួរព្រះអង្គពីទ្រឹស្តីកម្ម ធ្វើព្រះអង្គឲ្យចាស់ចាញ់យ៉ាងអាម៉ាស់មុខ។ ទីបំផុត បុច្ឆាវិសជ្ជនា ឧបាលិគហបតីប្រកាសជាឧឡារិកថា **កាយទណ្ឌ វចីទណ្ឌ មនោទណ្ឌ** ជាប្រវចនៈ **និគណ្ឋ នាដបុត្ត** មិនប្រសើរស្មើដោយ ពុទ្ធវចនគឺៈ **កាយកម្ម វចីកម្ម មនោកម្ម** នោះឡើយ ហើយសូមថ្វាយខ្លួនជាឧបាសកចូលសាសន៍ពុទ្ធរតន៍ បានដល់ត្រៃសរណគមន៍។ កាលនោះព្រះសម្ពុទ្ធទ្រង់ត្រាស់ទូន្មានឧបាលិគហបតី ឲ្យពិចារណាទុកមុនឲ្យបានម៉ត់ចត់សិន ព្រោះការពិចារណាម៉ត់ចត់ ទើបសម្រេចចិត្ត ជាការប្រសើរបំផុត តែឧបាលិគហបតី ទទូចសូមថ្វាយខ្លួនជាឧបាសក ទើបទ្រង់ប្រទានដំបូន្មាន សំឧបាលិគហបតីឲ្យគោរពគ្រូដើមរបស់ខ្លួនដូច

---

១ - ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ សៀវភៅទី១៦ ទំព័រ២១៣ តទៅ។

១ - មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ឧបាលិវាទសូត្រ សៀវភៅទី២៣ ទំព័រ៩។

ដើមដដែល។

បណ្ដា មេលទ្ធិសាសនាទាំងអស់ក្នុងលោក ព្រះសម្ពុទ្ធជាអគ្គបុគ្គលប្រសើរលើសក្នុងការប្រទានសេរីភាព ប្រទានខន្តីមេត្តាប្រោសប្រណី ប្រទានការយោគយល់ទៅវិញទៅមក។ ធម៌ទាំងនេះ ជាប្រពៃណីពុទ្ធសាសនារៀងរហូតមក។ ព្រះបាទអសោកមហារាជ ជាឧបាសកដ៏ប្រសើរបានយកធម៌ជាប្រពៃណីពុទ្ធសាសនា នេះមកប្រតិបត្តិក្នុងរជ្ជកាលព្រះអង្គ មានសេចក្ដីប្រាកដនៅក្នុងព្រះរាជប្រកាសព្រះអង្គស្រាប់ដូចសេចក្ដីតទៅនេះ[១] ៖

«អ្នកគ្រប់គ្នា មិនគួរលើកតម្កើងសរសើរតែលទ្ធិសាសនារបស់ខ្លួន ហើយប្រមូស្តលទ្ធិសាសនាដទៃទេ ត្រូវគោរពលទ្ធិសាសនាដទៃៗឲ្យដូចជាខ្លួនគោរពរបស់ខ្លួនដែរ។ ការគោរពលទ្ធិសាសនាដទៃៗឈ្មោះថា ជួយលើកតម្កើងហើយជួយពង្រីកលទ្ធិសាសនារបស់ខ្លួនផង ហើយធ្វើប្រយោជន៍ចំពោះលទ្ធិសាសនាដទៃផងដែរ បើមិនដូច្នេះទេឈ្មោះថាជីករណ្ដៅកប់លទ្ធិសាសនារបស់ខ្លួនឲ្យកប់បាត់ទៅ ព្រមទាំងធ្វើលទ្ធិសាសនាដទៃៗ ឲ្យវិនាសទៅផងដែរ។ អ្នកណាមួយគោរពតែលទ្ធិសាសនារបស់ខ្លួន ហើយប្រមូស្តលទ្ធិសាសនាដទៃ គ្រាន់តែបានឈ្មោះថា ធ្វើឲ្យគេឯងបានដឹងថាខ្លួនមានភក្តីភាពចំពោះលទ្ធិសាសនារបស់ខ្លួន ដោយគិតថា "អាត្មាអញបានលើកតម្កុំតម្កើងលទ្ធិសាសនារបស់ខ្លួនហើយ"។ គំនិតនេះខុសស្រឡះទេ ការប្រព្រឹត្តិនេះ ឈ្មោះថាបំផ្លាញលទ្ធិសាសនារបស់ខ្លួនដោយឥតសង្ស័យឡើយ។ ដូច្នេះ សាមគ្គីជាគុណធម៌ប្រសើរណាស់ សូមឲ្យអ្នកគ្រប់គ្នាស្តាប់ ហើយសូមមេត្តាស្តាប់វាទៈ នៃលទ្ធិសាសនាដទៃផង»។

ការសន្ដោសដោយសមានចិត្តនេះ ជាគុណធម៌ប្រសើរណាស់ ប្រសិនបើយកធម៌នេះមកអនុវត្តសម្រាប់ជាប្រយោជន៍ទូទៅ មិនមែនបានផលចំពោះតែលទ្ធិសាសនាទេ សូម្បីទុកជាច្បាប់សម្រាប់ប្រទេសជាតិ នយោបាយ សង្គមកិច្ច ឬ សេដ្ឋកិច្ច ក៏រឹងរឹតតែបានផលប្រយោជន៍ណាស់ទៅទៀត។

ខន្តីធម៌និងមេត្តាប្រោសប្រាណនេះ ជាឧត្តមគតិប្រសើរខ្ពង់ខ្ពស់ណាស់ ទុកជាវប្បធម៌និងអរិយធម៌នៃពុទ្ធសាសនា ចាប់ផ្ដើមតាំងពីពុទ្ធសាសនាកើតឡើង។ ការបៀតបៀន (**ហិង្សា** = La

---

១ -ព្រះរាជប្រកាស ព្រះបាទអសោកមហារាជ លេខ១២។

violence) ទោះជាបែបណាក៏ដោយ ឬ ទោះជាប្រើលេសមកបន្ទំក៏ដោយ ក៏សុទ្ធតែផ្ទុយនិងពុទ្ធវចនៈទាំងអស់។ ដោយពុទ្ធសាសនាមានលក្ខណៈ ប្រាកដដូច្នេះហើយ បានជាពិភពលោកមិនបានឃើញមានសង្គ្រាមការកាប់សម្លាប់គ្នាទុកជាឧទាហរណ៍ មានការស្រក់ឈាមមួយដំណក់ដោយការប្រកាសពុទ្ធសាសនា ឬ ផ្សាយពុទ្ធសាសនានេះឡើង នៅក្នុងប្រវត្តិសាស្ត្រពុទ្ធសាសនាដ៏វែងប្រមាណជា ២៥០០ឆ្នាំ ដែលកន្លងទៅនេះ។ សព្វថ្ងៃនេះ ពុទ្ធសាសនាផ្សាយទូទៅពេញទ្វីបអាស៊ី ហើយជ្រួតជ្រាបរហូតទៅដល់ទ្វីបអឺរ៉ុបនិងអាមេរិកទៀត មានអ្នកចូលកាន់សាសន៍ពុទ្ធរតន៍ប្រមាណជាប្រាំរយលាននាក់។

មានប្រស្នាមួយទៀតកើតឡើងរឿយៗ គេតែងចោទសួរថា ពុទ្ធសាសនាជាលទ្ធិសាសនា (Religion) ឬ ជាទស្សនវិជ្ជា (Philosophie ? មានអ្នកខ្លះ ឆ្លើយដែរ ឆ្លើយដោយអាការ ដូចអ្នកទស្សនវិទូ គេឆ្លើយថា ពុទ្ធសាសនាមិនមែនជាលទ្ធិសាសនា (Religion) ទេ និងជាទស្សនវិជ្ជា (Philosophie) ក៏មិនមែនទៀត ពុទ្ធសាសនាគឺ មិនមែនជាអ្វីទាំងអស់ ឬ និងថាជាអ្វីដូចអ្នកគិតនោះក៏មិនមែនដែរ ពុទ្ធសាសនា គឺពុទ្ធសាសនា។ សំនួរនេះ ជាការដាក់ស្លាកឬដាក់យីហោឲ្យពុទ្ធសាសនាមិនជាការអ្វីធំឬទាស់ខុសទេ ហៅថាដូចម្ដេចក៏បាន ពុទ្ធសាសនាមិនយកចិត្តទុកដាក់ចំពោះស្លាកឬយីហោ ដែលគេដាក់ឲ្យខ្លួននោះទេ។ ស្លាកឬយីហោ គ្រាន់តែជានាមបញ្ញត្តិ ស្លាកឬយីហោដែលគេសន្មតថា "ពុទ្ធសាសនានេះ ក៏មិនមានការសំខាន់អ្វីពេកណាស់ដែរ។ នាមដែលគេដាក់ឲ្យនេះ មិនមែនជាការសារវន្តទេ។

មានអ្វីក្នុងឈ្មោះ ឬហើយពីរោះ ?<br>
ដូចផ្កាកុលាប បើគេហៅអ្វី<br>
កុលាបពិសី ក្រអូបដដែល។

សច្ចធម៌មិនមានយីហោទេ គឺមិនមែនជាយីហោ «ពុទ្ធ គ្រិស្ត ហិណ្ឌូ មុស្លិម ឡៅត្សឺ ខុងត្សឺ ឈិនតូ» ទេ។ សច្ចធម៌មិនមែនជាឯកាធិភាព (Monopole) របស់ជនណាតែម្នាក់ទេ។ ស្លាក ឬយីហោថា និកាយនេះ និកាយនោះ ជានីវរណធម៌ រាំងបិទមិនឲ្យយល់សច្ចធម៌បាន ហើយបង្កើតជាឧបកិលេសដល់សន្តានចិត្តមនុស្ស ធ្វើចិត្តឲ្យសៅហ្មងទៀត។

សេចក្ដីពិតធម៌នេះមិនមែនផ្ដល់សេចក្ដីវិនាសឲ្យតែខាងលទ្ធិសាសនា ឬខាងបញ្ញាតែប៉ុណ្ណោះទេ ធ្វើឲ្យចូលរហូតទៅដល់ការទាក់ទងរវាងមនុស្សនិងមនុស្សទៀតផង ឧបមាថា យើងជួបមនុស្សម្នាក់យើងមិនមែនគ្រាន់តែទុកគេថាជាមនុស្សប៉ុណ្ណឹងទេ យើងថែមទាំងទៅដាក់ស្លាក ឬ យីហោឲ្យពាក់ទៀតថាគេ ជាអង់គ្លេស ជាបារាំង ជាអល្លឺមង់ ជាអាមេរិកកាំង ឬ ជាជិហ្វ ម៉្លោះហើយចិត្តយើងក៏ជាប់នៅក្នុងស្លាក ឬ យីហោនោះឯង។ ជួនកាលមនុស្សដែលយើងសំគាល់នោះមិនមែនជាជាតិដែលយើងដាក់ស្លាក ឬ យីហោឲ្យនោះផង។

មនុស្សលោកចូលចិត្តដាក់ស្លាក ឬ យីហោណាស់ ដាក់រហូតទៅដល់គុណធម៌ដ៏ប្រសើររបស់មនុស្សលោកទៀត។ នេះជាសន្ដានចិត្តនៃមនុស្សសាមញ្ញទូទៅក្នុងពិភពលោក។ ដូច្នេះហើយ បានជាយើងឃើញមានស្លាក ឬ យីហោ នៃការឲ្យទាន (Charité) គេថា នេះទានពុទ្ធទានគ្រិស្ដ ទានហិណ្ឌូ ហើយមើលងាយទាននៃជនទាំងនោះថាជាទានមិនមានអានិសង្ស។ សេចក្ដីពិតទានគឺទាន ប្រាកដជាទាន។ ទាន មិនមែនជាពុទ្ធ ជាគ្រិស្ដ ជាហិណ្ឌូ ឬ ជាមុស្លិមទេ។ ព្រហ្មវិហារធម៌នៃមាតាបិតា មិនមែនជាពុទ្ធ មិនមែនជាគ្រិស្ដ មិនមែនជាហិណ្ឌូ ឬ ជារបស់អ្នកណាទេ គឺជារបស់មាតាបិតា។ គុណធម៌ ឬ ទោសធម៌ដែលកើតក្នុងសន្ដានចិត្តមនុស្ស ដូចសិនេហធម៌ សប្បុរសធម៌ ករុណា ខន្តី វិរិយៈ មិត្តភាព រាគៈ ទោសៈ មោហៈ មានៈ ធម៌ទាំងអស់នេះ មិនមែនជាស្លាក ឬ យីហោនៃនិកាយទេ មិនមែនជាធម៌នៃលទ្ធិសាសនាណាមួយចំពោះទេ។ បុណ្យ បាប ដែលកើតឡើង កុសលចិត្តនិងអកុសលចិត្ត មិនមែនកើតចំរើនឡើង ឬ អន់ថយទៅវិញ ដោយសារតែយើងជួបមនុស្សដែលកាន់លទ្ធិសាសនានោះទេ។

អ្នកស្វែងរកសច្ចធម៌ មិនមានប្រយោជន៍អ្វីនឹងដឹងថា សច្ចធម៌នេះកើតមកពីណាទេ។ ការរកកំណើត ឬ ការចំរើនឡើងនៃឧត្តមគតិនេះជាភារៈនៃអ្នកប្រវត្តិសាស្ត្រដោយឡែក។ ដើម្បីលុះសច្ចធម៌ មិនបាច់នឹងដឹងថា ពុទ្ធវចនៈនេះ ជាធម៌អង្គព្រះសម្ពុទ្ធ ឬ របស់លោកអង្គណាក៏បាន។ កិច្ចការដែលជាសារវន្តនោះ គឺការឃើញធម៌ពិត ហើយបានលុះធម៌នោះដោយប្រពៃ សេចក្ដីនេះមានឧទាហរណ៍ពិតប្រាកដនៅគម្ពីរមជ្ឈិមនិកាយ [១] ដូចសេចក្ដីតទៅនេះ ៖។

---

១ - មជ្ឈិមនិកាយ ឧបរិបណ្ណាសក ធាតុវិភង្គសូត្រ សៀវភៅទី២៨ ទំព័រ១៧០។

ថ្ងៃមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថ អស់រាត្រីមួយ ក្នុងរោងកុម្ភការ ទ្រង់បានជួបឫសីក្មេងម្នាក់ ដែលចូលមកនៅក្នុងរោងនោះមុនព្រះអង្គ។ ព្រះអង្គក្តី ឫសីក្មេងក្តី ទាំងពីរនាក់នេះ មិនបានស្គាល់គ្នាទេ។ លុះទតព្រះនេត្រឃើញឫសីក្មេងនោះហើយ ព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះថា : "ចរិយាឫសីនេះ ស្រគត់ស្រគមសមរម្យមល្អណាស់មើលទៅមុខគួរឲ្យជ្រះថ្លា គួរនឹងបានផលល្អ ប្រសើរបើតថាគតសាកសួរមើល"។ ទ្រង់ព្រះតម្រិះហើយទ្រង់ត្រាស់ក្វាងសួរថា:

"នែឫសី ! អ្នកចេញចាកផ្ទះហើយមកបួសនេះ តើអ្នកបួសចំពោះលោកណា? លោកណាជាសាស្តារបស់អ្នក? តើវាទទៈលោក នោះដូចម្តេច?

បានឮពុទ្ធដីកាហើយ ឫសីក្មេងនោះ ឆ្លើយតបពុទ្ធដីកាដោយអាការជា គ្នាវ៉ារធម្មតាថា :

"ឱសម្លាញ់អើយ ! មានឫសីមួយអង្គនាមថា **គោតម** ជាសាក្យដោយជាតិ ព្រះអង្គចេញចាកសាក្យត្រកូល ហើយមកបួសកាន់យកភេទជាឫសី ព្រះអង្គមានកិត្តិនាមល្បីខ្ចរខ្ចាយទូទៅថាជាព្រះអរហន្តបានត្រាស់ដឹងធម៌ ជាសម្មាសម្ពុទ្ធ ខ្ញុំឮហើយជ្រះថ្លា ខ្ញុំចេញចាកផ្ទះមកបួសកាន់យកភេទជាឫសីចំពោះព្រះអង្គ ព្រះអង្គជាសាស្តាខ្ញុំ ខ្ញុំពេញចិត្តចំពោះវាទរបស់ព្រះអង្គនេះ"។

"ចុះព្រះអង្គ, ទ្រង់ត្រាស់សួរទៀត, ជា**អរហន្ត** ជា**សម្មាសម្ពុទ្ធ** ដែលអ្នកយកធ្វើជាសាស្តាខ្លួនអ្នកនោះ ឥឡូវនេះទ្រង់គង់នៅទីណា?

"ឱសម្លាញ់អើយ !, ឫសីក្មេងឆ្លើយតបវិញ, បានឮថាមានអារាមមួយនៅឯឧត្តរប្រទេស ជិតក្រុង **សាវត្ថី** ព្រះអង្គជា**អរហន្ត** ជា**សម្មាសម្ពុទ្ធ** ជាសាស្តារបស់ខ្ញុំ ព្រះអង្គប្រថាប់នៅទីនោះ។

"នែឫសីក្មេង !, ទ្រង់ត្រាស់បញ្ជាក់, ចុះអ្នកដែលបានឃើញសាស្តារបស់អ្នកនោះដែរឬទេ?

"ទេសម្លាញ់ !, ឫសីក្មេងបញ្ជាក់ទូល ខ្ញុំមិនដែលបានឃើញ ឬបានជួបព្រះអង្គទេ កុំថាឡើយឃើញ គ្រាន់តែស្គាល់ព្រះអង្គ ខ្លួនខ្ញុំក៏មិនដែលទាំងបានស្គាល់ព្រះអង្គផង"។

ពេលនោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ឫសីក្មេងនេះបួសកាន់យកភេទជាតាបសចំពោះធម្មវិន័យព្រះអង្គ ទើបទ្រង់ត្រាស់ថា ៖

"នែភិក្ខុ ! តថាគតនឹងទេសនា អ្នកប្រុងស្តាប់ចុះ !"។ តទៅទ្រង់សំដែង **អរិយសច្ច** ប្រោសប្រទានចប់ **ធម្មីកថា** ហើយ ឫសីក្មេងនោះបានលុះអរហត្តផល។ ទីបំផុត ទាំងអស់គ្នាបានស្គាល់

ថា ឫសីក្មេងនោះគឺ **បុក្កុសាតិភិក្ខុ** អ្នកប្រទានធម្មទេសនានោះ គឺអង្គព្រះសម្ពុទ្ធ។ ពេលនោះ **បុក្កុសាតិភិក្ខុ** ឱនក្រាបទៀបបាទាអង្គព្រះសម្ពុទ្ធ ហើយលើកកម្ចង់អញ្ជលីក្រាបទូលសូមខមាទោស ដោយខ្លួនពុំបានដឹងថាជាអង្គព្រះសម្ពុទ្ធ បានភ្ញាត់ពោលពាក្យហៅព្រះអង្គថា "សម្លាញ់"។ តទៅ **បុក្កុសាតិ** ក្រាបទូលអង្គព្រះសម្ពុទ្ធ សុំបព្វជ្ជាជាភិក្ខុក្នុងសំណាក់ពុទ្ធសាសនា តែពេលនោះ **បុក្កុសាតិ** មិនមានត្រៃចីវរ មិនមានបាត្រ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់បង្គាប់ឲ្យរកត្រៃចីវរ រកបាត្រ តាមប្រពៃណីពុទ្ធសាសនា។ **បុក្កុសាតិ** ក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធ ហើយដើរទៅស្វែងរកត្រៃចីវរនិងបាត្រ កំពុងតែដើរស្វែងរក មានគោញីមួយមកដល់លោក ហើយលោកធ្វើមរណកាលទៅ។

តមកថ្ងៃក្រោយទៀត ព្រះសម្ពុទ្ធទ្រង់បានជ្រាបថា **បុក្កុសាតិភិក្ខុ** នោះគោញីដល់ហើយធ្វើមរណកាលទៅហើយ ទើបទ្រង់ត្រាស់ថា : "**បុក្កុសាតិភិក្ខុ** នេះជាអ្នកប្រាជ្ញ បានឃើញអរិយសច្ចធម៌ហើយ បានដល់ឈានថ្នាក់ខ្ពស់បំផុត ដែលត្រូវសម្រេចនិព្វានជាអរហន្ត និព្វានហើយមិនត្រឡប់មកកាន់ភពនេះទៀតទេ"។

និទាននេះ បញ្ជាក់សេចក្តីច្បាស់លាស់អស់ដើងហើយថា **បុក្កុសាតិភិក្ខុ** បានស្តាប់ធម៌អង្គព្រះសម្ពុទ្ធ ហើយបានត្រាស់ដឹងធម៌ព្រះអង្គហើយ។ ភិក្ខុ **បុក្កុសាតិ** នេះ មិនបានស្គាល់ថាអ្នកណាជាអ្នកសម្តែងធម៌ដល់ខ្លួនទេ តែលោកស្តាប់ហើយមានភ្នែក ឃើញសច្ចធម៌ពិតប្រាកដ។ **បុក្កុសាតិភិក្ខុ** បានឃើញធម៌ ហើយបានលុះអរហត្តផល ចូលនិព្វានទៀតតើបានដោយមានស្លាក ឬ យីហោ? បើថ្នាំសក្តិសិទ្ធិហើយ ជម្ងឺមុខតែជាសះស្បើយពិតប្រាកដពុំខាន មិនបាច់ដឹងថាពេទ្យណាជាអ្នកផ្សំថ្នាំ ឬ ថ្នាំនោះបានមកពីលោកណាទេ។ ដូច្នេះសច្ចធម៌ មិនពឹងផ្អែកទៅលើស្លាក ឬ យីហោឡើង។

លទ្ធិសាសនាស្ទើរតែទាំងអស់ សុទ្ធតែកកើតឡើងដោយជំនឿ (Foi, croyance) យកជំនឿ ឬ "ជំនឿខ្វាក់" ទុកជាបានលទ្ធិសាសនាហើយពឹកផ្អែកទៅលើព្រះអាទិទេព ព្រមទាំងលាក់ព្រះអាទិទេពនៅឯឋានសួគ៌ ហើយផ្សាយជំនឿឲ្យគេជឿតាម។ ជំនឿបែបនេះ ជាជំនឿឥតហេតុផល ជាជំនឿឥតបើគិត។ ឯជំនឿក្នុងពុទ្ធសាសនា ផ្ទុយគ្នាស្រឡះជាជំនឿប្រកបដោយ

ហេតុផល (Cause et effet) ជាជំនឿប្រកបទៅដោយវិចារណញ្ញាណ (Raisonnement) ពោលគឺ **សទ្ធា** = ជំនឿដែលប្រកបដោយបញ្ញា Confiance = Confidence et sagess = winsdom)។ ជំនឿពុទ្ធសាសនានេះ សំដៅយក ការឃើញច្បាស់ ការដឹងច្បាស់, ការយល់ជាក់ច្បាស់ "មិនមែនសំដៅយកជំនឿបែប "Foi, Croyance; Faith, Belief" ដូចពាហិរសាសនាទាំងអស់នោះទេ។ សព្វថ្ងៃនេះយើងប្រើពាក្យច្របូកច្របល់គ្នាណាស់ ដូចពាក្យថា "Religion" យើងប្រែថា "សាសនា" ឬ ពាក្យថា "Foi, Croyance ជាបារាំង, Faith, Belief ជាអង់គ្លេស យើងប្រែថា "ជំនឿ ពោលគឺសទ្ធា" តែសេចក្តីពិត ពាក្យថា "សទ្ធា = ជំនឿ" ក្នុងពុទ្ធសាសនាមិនមែនមានអត្ថន័យដូចពាក្យ "Foi, Croyance; Faith, Belief" ក្នុងសទ្ធិសាសនាគ្រិស្ត ឥស្លាម ព្រាហ្មណ៍ នោះទេ។ សទ្ធា = ជំនឿក្នុងពុទ្ធសាសនាជាជំនឿបែប "Confiance, Confidence" ជាជំនឿដែលកើតចេញពីការជឿជាក់ (Conviction) ការជ្រះថ្លា (Joi ou sereine) ទុកជាសរណៈ ការទីពឹងដ៏ប្រសើរ (Refuge) ដូចសទ្ធា ជឿជាក់ ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើម។ ការជឿជាក់ច្បាស់មិនកម្រើក, សេចក្តីជ្រះថ្លាចំពោះកុសលធម៌, ការទុកចិត្តដោយយល់ច្បាស់ថានឹងបានសម្រេចដូចបំណង ក៏លោកទុកថាជា សទ្ធា = ជំនឿដែរ។ ធម៌ ២ ប្រការគឺ សទ្ធា និង បញ្ញា ជាធម៌គូគ្នា គឺបើមានសទ្ធាត្រូវមានបញ្ញា។ អ្នកជឿ មិនមានបញ្ញានិងដើរវង្វេងផ្លូវ។ អ្នកមានសទ្ធា មិនប្រើបញ្ញាពិចារណារកខុសត្រូវ គិតតែពីជឿ នឹងធ្លាក់ទៅជាមនុស្សល្ងង់។ រីអ្នកមិនមានសទ្ធា មិនមានជំនឿទេ ធ្វើអ្វីៗ អាងបញ្ញាគិតពិចារណា បើបញ្ញាខ្លួនគិតចាក់មិនធ្លុះ និងធ្លាក់ខ្លួនទៅជាអ្នកយល់ខុស គឺទៅជាអ្នក **មិច្ឆា**។ អ្នកដើរក្នុងលោកងងឹតនេះ ត្រូវប្រើធម៌ ២ ប្រការគឺសទ្ធា និង បញ្ញានេះ និងខានពុំបានឡើយ ទើបដើរទៅមិនវង្វេងកណ្តាលអធ្វា។

សទ្ធា = ជំនឿ ដែលប្រកបដោយបញ្ញា ពិចារណាឃើញពិតដឹងពិត យល់ពិត នូវកិច្ចការអ្វីមួយដែលបុគ្គលត្រូវការធ្វើ ជាពលៈ = មានសទ្ធាពល មានកម្លាំងខ្លាំងបំផុត ជាហេតុនាំឲ្យសម្រេចសេចក្តីប្រាថ្នាពិតប្រាកដ។ បុគ្គលដែលធ្វើកិច្ចការអ្វីមួយ ហើយមិនបានសម្រេចសមតាមក្តីប្រាថ្នា មិនមែនដោយខ្វះអ្វីទេ គឺខ្វះធម៌ ២ ប្រការនេះឯង។

ព្រះបរមពោធិសត្វ ដែលបានសម្រេចភាវៈជាព្រះសម្ពុទ្ធ ក៏ដោយសទ្ធា ដែលប្រកបដោយ

*បញ្ញា ចាប់ដើមតាំងពីទ្រង់តាំងព្រះទ័យកសាងបារមីធម៌ ឲ្យបានសម្រេចសម្មាសម្ពោធិញ្ញាណ។ សទ្ធានោះហៅថា* **អាគមសទ្ធា**។

*ព្រះអរហន្តគ្រប់អង្គ ក៏មានសទ្ធាដែលប្រកបដោយបញ្ញា ទើបបានលុះធម៌ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងទុកមក។ សទ្ធានេះ ហៅថា* **អធិគមសទ្ធា**។

*ឯការជឿជាក់ច្បាស់ មិនកម្រើកចំពោះគុណព្រះរត្នត្រ័យ ក៏ដោយសទ្ធាដែលប្រកបដោយបញ្ញាដែរ។ សទ្ធានេះ ហៅថា* **ឱកប្បនសទ្ធា**។

*ចិត្តដែលជ្រះថ្លាចំពោះអំពើជាកុសល ដោយបានយកបញ្ញាពិចារណាឃើញពិត ដឹងពិត យល់ពិត ថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ នេះហៅថា* **បសាទសទ្ធា**។

*សទ្ធាដែលប្រកបដោយបញ្ញានេះ ជាទ្រព្យដ៏ប្រសើររបស់មនុស្សក្នុងលោក* **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** *ជំនឿនេះ មានតម្លៃណាស់ ស្មើជីវិត មិនគួរនឹងជឿអ្វីៗ ឥតបើគិតទេ។ បុគ្គលជឿឥតបើគិតនេះ មានទោសដល់ស្លាប់។ ដូច្នេះជំនឿដទៃៗ បែប* Foi, Croyance; Faith, Belief *តែងកើតឡើងតែក្នុងពេលណា ដែលគេមិនទាន់ឃើញពិត ដឹងពិត យល់ពិត, ក្នុងពេលណាដែលគេបានឃើញពិតបានដឹងពិតបានយល់ពិតហើយ ប្រស្នាជំនឿនេះនឹងរលត់បាត់ទៅឯងឧបមាថា មានមនុស្សម្នាក់មកនិយាយប្រាប់ថា "ខ្ញុំមានពេជ្រមួយគ្រាប់នៅក្នុងក្ដាប់ដៃខ្ញុំនេះក្នុងពេលដែលឮពាក្យនេះ" ប្រស្នាជំនឿទើបកើតឡើង ព្រោះមិនទាន់បានឃើញពេជ្រនោះ ដោយភ្នែកខ្លួនឯងនៅឡើយ គ្រាន់តែឮគេនិយាយប្រាប់។ កាលបើអ្នកនិយាយនោះលាក្ដាប់ដៃបង្ហាញពេជ្រនោះហើយ យើងឃើញពេជ្រនោះដោយភ្នែក នឹងថាជាពេជ្រពិតមែនយល់ច្បាស់ថាជាពេជ្រពិតមែន ពេលនោះប្រស្នាជំនឿបែប* Foi, Croyance; Faith, Belief *រលត់បាត់ឯងលែងកើតមានទៀតហើយ។ សេចក្ដីនេះដូចជារឿងដែលយើងធ្លាប់បានឮមកថា "បានសម្រេចដូចជាគេបានឃើញពេជ្រនៅលើបាតដៃ"។ ដូច្នេះ គួរគប្បីយល់ថា ជំនឿដែលកើតមានឡើង កើតមានតែក្នុងពេលណា ដែលយើងមិនទាន់ឃើញ មិនទាន់ដឹង មិនទាន់យល់ បើឃើញហើយដឹងហើយ យល់ច្បាស់ហើយ ប្រស្នាជំនឿនេះនឹងបាត់ទៅឯងវិញ មិនមានជាប្រស្នាចោទឡើងទៀតទេ ក្នុងគម្ពីរបាលីពុទ្ធសាសនា មិននិទានជាឧទាហរណ៍ច្រើនអន្លើណាស់សម្រាប់បញ្ជាក់សេចក្ដីខាងលើនេះ ដូច*

និទានទៅនេះ [១] ។

សម័យមួយ ព្រះ **មុសិលត្ថេ** គង់នៅវត្ត **ឃោសិតារាម** ជិតក្រុង **កោសម្ពី** មានថេរដីកាចំពោះព្រះបវិដ្ឋត្ថេរ ថា :

"**អាវុសោ បវិដ្ឋ** ! បើបុគ្គលណាមួយមិនមានធម៌ ៥ ប្រការ :

- **សទ្ធា** = ជំនឿ គឺជំនឿទូទៅតាមធម្មតា តាមអត្ថានុរូបរបស់សព្ទថា "សទ្ធា" មានអត្ថន័យដូច Dévotion, Foi, Croyance; Faith, Belief

- **រុចិ** = ការពេញចិត្ត (Penchant ou inclination = Liking or inclination)

- **អនុស្សវា** = ការឮតៗគ្នា (Oui-dire ou tradition = Hear say or tradition)

- **អាការបរិវិតក្ក** = ការត្រិះរិះដោយអាការ (Considérer les raisons apparentes = Considering apparent reason)

- **ទិដ្ឋិនិជ្ឈានក្ខន្តិ** = ការចូលចិត្តតាមការយល់ឃើញ (Se complaire dans les spéculations des opinions = Delight in the speculations of opinions)

ខ្ញុំដឹងថា ខ្ញុំឃើញថា ជរា ព្យាធិ មរណៈ រលត់ព្រោះ**ជាតិ**រលត់, **ជាតិ**រលត់ ព្រោះ**ភព**រលត់, **ភព**រលត់ព្រោះ**ឧបាទាន**រលត់, **ឧបាទាន**រលត់ព្រោះ**តណ្ហា**រលត់, **តណ្ហា**រលត់ព្រោះ**វេទនា**រលត់, **វេទនា**រលត់ព្រោះ**ផស្ស**រលត់, **ផស្ស**រលត់ព្រោះ**សឡាយតន**រលត់, **សឡាយតន**រលត់ព្រោះ**នាមរូប**រលត់, **នាមរូប**រលត់ព្រោះ**វិញ្ញាណ**រលត់, **វិញ្ញាណ**រលត់ព្រោះ**សង្ខារ**រលត់, **សង្ខារ**រលត់ព្រោះ**អវិជ្ជា**រលត់។

«**អាវុសោ មុសិល** ! ព្រះបវិដ្ឋត្ថេរសួរបញ្ជាក់, បើមិនមានធម៌ ៥ ប្រការខាងលើនេះ តើ**មុសីល**មានអាយុ មានញាណឃើញច្បាស់ក្នុងខ្លួនថា ភពរលត់ **ភវនិរោធ** គឺនិព្វានដូច្នេះឬ?

«**អាវុសោ បវិដ្ឋ**, ព្រះមុសិលត្ថេរតប, បើមិនមានធម៌ ៥ ប្រការនេះទេខ្ញុំដឹង ខ្ញុំឃើញថា "**ភពរលត់ ជានិព្វាន = ភវនិរោធោនិព្វានំ**"។

«**អាយស្មា មុសល** ! ព្រះ**បវិដ្ឋត្ថេរ** បញ្ជាក់ថែមទៀត, បើដូច្នោះមានតែ **មុសិល** ដ៏មាន

---

១ - សំយុត្តនិកាយ និទានវគ្គ សៀវភៅទី៣១ ទំព័រ២៤៧។

*អាយុ ជាព្រះអរហន្តខីណាស្រពឬ?*

*កាលព្រះ* **បរិជ្ជត្ថេរ** *សួរបញ្ជាក់ថែមទៀតយ៉ាងនេះហើយ ព្រះ***មុសិលត្ថេរ** *គង់នៅស្ងៀម មិននាំពាតទៅទៀត។*

*សទ្ធានេះ មិនមាននៅសន្តានចិត្តព្រះអរហន្តទេ ដូចសេចក្តីតទៅនេះ*[១]*។*

*សម័យមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចឥរិយាបថ នៅវត្ត***ជេតវនារាម** *ជាអារាមអានាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ជិតក្រុងសាវត្ថី។ កាលនោះ ព្រះសម្ពុទ្ធមិលមើលឃើញឧបនិស្ស័យភិក្ខុ ៣០រូប ទ្រង់ប្រារព្ធបញ្ចិន្ទ្រិយ ហើយត្រាស់ចំពោះព្រះ* **សារិបុត្តថា** :

«**សារីបុត្ត** ! *អ្នកមានសទ្ធា = ជំនឿចំពោះសទ្ធិន្ទ្រិយ ដែលតថាគតបានភាវនាហើយ ចុះស៊ប់ក្នុង* **អមតនិព្វាន** *មាន***អមតនិព្វាន** *ជាបរិយោសានដែរឬទេ?។*

«*សូមទ្រង់ព្រះមេត្តាប្រោស ! បុគ្គលណា មិនបានដឹង មិនបានសិក្សា មិនបានឃើញ មិនបានត្រាស់ដឹង មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់សេចក្តីនេះដោយបញ្ញាខ្លួនឯងទេ បុគ្គលនោះតែងលុះដោយសទ្ធានៃបុគ្គលដទៃថា* **សទ្ធិន្ទ្រិយ** *ដែលបុគ្គលដទៃបានភាវនាហើយ ។ល។ មាន***អមតនិព្វាន**» *ជាបរិយោសាន ដូច្នោះឯង។*

*កាលនោះ ភិក្ខុទាំងឡាយបបួលគ្នានិយាយអឺងកង់ឡើងថា ព្រះ***សារីបុត្តត្ថេរ** *ក្រាបទូលតបស្នងព្រះពុទ្ធដីកាអំបាញ់មិញនេះ ដោយការយល់ឃើញខុសទេ។ ថ្ងៃនេះ ព្រះ***សារីបុត្តត្ថេរ** *មិនមានសទ្ធាជឿអង្គព្រះសម្ពុទ្ធឡើយ។ សេចក្តីនេះបានជ្រាបដល់ព្រះកាណ៌អង្គព្រះមានបុណ្យទើបទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា* :

«*ភិក្ខុទាំងឡាយ ! តថាគតសួរ* **សារីបុត្ត** *ថាបុគ្គលដែលមិនបានភាវនាបញ្ចិន្ទ្រិយ មិនបានចម្រើន* **សមថវិបស្សនា** *តើអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គផលបានឬទេ ដូច្នេះទេតើ។ ពេលនោះ ព្រះ***សារីបុត្ត***ឆ្លើយតបមកតថាគតវិញថា* :

«*សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គមិនមានសទ្ធាជឿថា "បុគ្គលនេះអាចធ្វើឲ្យជាក់ច្បាស់បាន,* **សារីបុត្ត** *មិនមានសទ្ធាជឿផលវិបាកដែលគេឲ្យ ឬ ផលវិបាកដែលគេធ្វើ, មិនមាន*

---

១ - គម្ពីរធម្មបទ។

*សទ្ធាជឿគុណព្រះ***អរិយបុគ្គល** *មានអង្គព្រះសម្ពុទ្ធជាដើមដូច្នេះទេ"។* **សារីបុត្ត** *មិនមានសទ្ធាយ៉ាងនេះព្រោះ* **សារីបុត្ត** *បានឈាន***វិបស្សនា** *មគ្គផលខ្លួនឯងហើយ មិនលុះដោយសទ្ធានៃអ្នកដទៃទៀតទេ។ ដូច្នេះអ្នកទាំងឡាយមិនគួរលើកទោស* **សារីបុត្ត***ឡើយ មានពុទ្ធដីកាហើយទ្រង់ត្រាស់ថា :*

**អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ ហតាវកាសោ វន្តាសោ ស វេ ឧត្តមចោរិសោ។**

*លោកណាអស់សទ្ធា បានលុះនិព្វាន អស់កំណើត អស់ពូជបុណ្យបាប មានករណីយកិច្ចធ្វើហើយ លោកនោះ ជាឧត្តមបុរស*

*សេចក្តីនេះ បញ្ជាក់យ៉ាងច្បាស់លាស់ថា : "ព្រះអរហន្ត មិនមានសទ្ធាទេ ព្រះអរហន្តលះបង់ចោលសទ្ធាអស់ហើយ"។ មួយទៀត សេចក្តីនេះបញ្ជាក់ច្បាស់លាស់ថា : "ព្រះសម្ពុទ្ធមានព្រះទ័យទូលំទូលាយណាស់ទ្រង់ប្រទានសេរីភាពដ៏បរិបូណ៌ដល់សាវកព្រះអង្គ សាវកព្រះអង្គអាចពោលដោយសេរីចំពោះព្រះភក្រ្តព្រះសាស្តារបស់ខ្លួន តាមសេចក្តីពិតដែមាខ្លួនបានឃើញពិត"។ ព្រះសម្ពុទ្ធតែងទ្រង់ត្រាស់ថា*[១] *:*

*ភិក្ខុទាំងឡាយ ! បុគ្គលណាបានកំចាត់បង់នូវឆន្ទរាគ និងឧបកិលេសអស់រលីងហើយ បុគ្គលនោះ បានឃើញ មិនបានដឹង មិនបានយល់ច្បាស់ នោះឥតអង្គឹមានឡើយ។*

*ប្រស្នាសទ្ធា = ជំនឿ នេះ និយាយចំពោះតែការឃើញច្បាស់ ដឹងច្បាស់តែប៉ុណ្ណោះទេ មិនមាននិយាយពីជំនឿតាមធម្មតានោះទេ។ សេចក្តីនេះព្រះសម្ពុទ្ធបានថ្លែងបញ្ជាក់ដោយពុទ្ធចវនៈថា "***ឯហិ បស្សិកោ** *បានសេចក្តីថា ចូរអ្នកចូលមក ! ហើយមើលដោយខ្លួនឯងចុះ"* មិនមែនហៅ*ឲ្យចូលមក ហើយឲ្យជឿដូចពាហិរសាសនាទាំងឡាយទេ។*

*គោលធំបំផុតក្នុងពុទ្ធសាសនា ដោយពិត និយាយចំពោះតែការត្រាស់ដឹងអរិយសច្ច ដែលព្រះសម្ពុទ្ធប្រើពាក្យថា : "***ធម្មចក្ខុ** = *ភ្នែកធម៌ ឬ មានភ្នែកឃើញធម៌"* កើតឡើង, បានសេចក្តីថា *"ភ្នែកមានធូលីគឺរាគៈ ទៅប្រោសហើយ បានឃើញសច្ចធម៌ បានលុះសច្ចធម៌ បានត្រាស់ដឹង*

---

១ - សំយុត្តនិកាយ កិលេសសំយុត្ត សៀវភៅទី៣៤ ទំព័រ១៧៥។

*សច្ចធម៌ បានចាក់ធ្លុះសច្ចធម៌ មានក្ដីសង្ស័យកន្ទង់ផុតហើយ ឃើញអ្វីៗ ឃើញដោយបញ្ញាចក្ខុ ដោយពិត ទៅតាមពិត* = **យថា ភូតំ ញាណ ទស្សនំ, យថាភូតទស្សនញាណ។** *បើតាមសេចក្ដីដែលយើងបានសិក្សាគម្ពីរដីកាពុទ្ធសាសនា យើងបានឃើញថា ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងបឋមទេសនាថា* [១] *"ភ្នែក កើតហើយ ញាណ កើតហើយ បញ្ញា កើតហើយ វិជ្ជា កើតហើយ ពន្លឺកើតហើយ* = **ចក្ខុំ ឧទចាទិ ញាណំ ឧទចាទិ បញ្ញា ឧទចាទិ វិជ្ជា ឧទចាទិ អលោកោ ឧទចាទិ**"។ *ដូច្នេះ ពុទ្ធសាសនា និយាយតែពីការឃើញច្បាស់ដោយ* **ញាណទស្សនៈ** *មិនមែននិយាយជំនឿដូចជំនឿ* = Croyance Foi; Faith, Belief *នោះទេ។*

*ប្រស្នាជំនឿនេះ មានច្រើនអន្ទើណាស់។ ក្នុងសម័យពុទ្ធកាលមានព្រាហ្មណ៍ច្រើននាក់ សុទ្ធតែជាអ្នកគន្ថបដិបន្នតឹងរឹង* (Orthodox) *បានប្រកែកជជែកគ្នាតឹងក ក្នុងការប្រើជំនឿទៅតាមប្រពៃណី ដែលខ្លួនធ្លាប់តែប្រកាន់ជឿតៗមក ហើយដែលខ្លួនចុះចិត្តស៊ប់ជឿថា ជាសច្ចៈឯកមិនមានប្រស្នាចោទតវ៉ាឡើយ។ ថ្ងៃមួយ មានពួកព្រាហ្មណ៍អ្នកប្រាជ្ញច្រើននាក់ សុទ្ធតែបានដល់ត្រើយនៃត្រៃវេទ* [២] *ជជែកគ្នាពីប្រស្នាជំនឿនេះមិនដាច់ស្រេច បានចូលទៅគាល់ព្រះមានបុណ្យ ហើយលើកប្រស្នាជំនឿមកសាកសួរដេញដោល។ បណ្ដាព្រាហ្មណ៍ទាំងនោះ មានព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេ អាយុទើបតែបាន ១៦ឆ្នាំ ឈ្មោះ***កាបធិកា** *ជាព្រាហ្មណ៍មានការចេះដឹងប្រសើរជាងគេ គេទុកជាព្រាហ្មណ៍ឯក មានប្រាជ្ញាភ្លឺថ្លា បានចោទដណ្ដឹងព្រះមានបុណ្យថា :* [១]*។*

*បពិត្រព្រះមានបុណ្យ ! មានគម្ពីរព្រាហ្មណ៍ គឺគម្ពីរ* **វេទ** *គេបានរក្សាទុកតៗមកដោយប្រពៃតាមមុខបាឋតាមប្រពៃណី។ គម្ពីរ***វេទ***នេះ ព្រាហ្មណ៍គ្រប់គ្នាបានយល់គ្រប់គ្នាជាឯកច្ឆន្ទថា :* "**មន្ត្រវេទ** *នេះជាសច្ចឯក មិនមានពីរទេ* = **ឯកំសធី អាទិ្វតីយម** *ដទៃពីនេះសុទ្ធតែជាធម៌ខុស មិនមែនជាសច្ចៈទេ"។ សេចក្ដីនេះតើព្រះសមណគោតម តាមសេចក្ដីយល់ឃើញថាដូចម្ដេច?*

*ព្រះសម្ពុទ្ធទ្រង់ព្រះសណ្ដាប់ហើយ ត្រាស់ភ្លាង តបទៅវិញថា : ។*

---

១ - .................។

២ - ព្រាហ្មណ៍អ្នកប្រាជ្ញសុទ្ធតែចេះវិជ្ជាព្រាហ្មណ៍គ្រប់ប្រការ មានគម្ពីរ៥ ជាដើម គឺគម្ពីរនិរបុណ្ឌ, អាក្ខារបភេទ, អក្ខារបភេទ, ភេដុភ, សិក្ខា និង និរុត្តិ, ឥតិពាន:។

១ - មជ្ឈិមនិកាយ ចង្កីសូត្រ មជ្ឈិមបណ្ណាសក សៀវភៅទី២៥ ទំព័រ១១៤។

«**ការទ្វាជៈ** ! បណ្ដាព្រាហ្មណ៍ទាំងអស់ មានព្រាហ្មណ៍ណាម្នាក់ ដែលអួតអាងថាខ្លួនបាន ដឹងច្បាស់ បានឃើញច្បាស់ដោយភ្នែកខ្លួនឯងថា **មន្ត្រវេទ** នេះជាសច្ចឯកមិនមានពីរទេ ដទៃពី នេះសុទ្ធតែជាធម៌ខុសដែរឬទេ?

«មិនមានទេ ទានប្រោស ! កាបទិកព្រាហ្មណ៍នេះ ជាក្មេងស្មោះត្រង់ឆ្លើយតបពុទ្ធដីកាថា, ឥតមានព្រាហ្មណ៍ណាម្នាក់បានដឹង បានឮ បានឃើញដោយភ្នែកខ្លួនឯងទេ»។

«**ភារទ្វាជៈ** ! ព្រះសម្ពុទ្ធត្រាស់សួរតទៅទៀត, ចុះមានអាចារ្យណាម្នាក់ ឬ អាចារ្យតពី អាចារ្យដើម ដែលជាព្រាហ្មណ៍មានអាយុវែងរហូតដល់ប្រាំពីរជួរគោត្រ ឬ ក៏ឫសីដើម [១] ដែល បានចងក្រងគម្ពីរ**វេទ**ទុកមក ហើយអួតអាងថាខ្លួនបានដឹងច្បាស់ បានឮច្បាស់ បានឃើញច្បាស់ ដោយភ្នែកខ្លួនឯងថា **មន្ត្រៈវេទ** ជាសច្ចឯកមិនមានពីរទេ ដទៃពីនេះសុទ្ធតែជាធម៌ខុសដែរឬ ទេ?»។

«ទេ ! ទេ ! ទានប្រោស កាបទិកព្រាហ្មណ៍ក្មេងក្រាបទូលតបពុទ្ធដីកា, មិនមានអ្នកណា បាន ដឹង បានឮ បានឃើញដោយភ្នែកខ្លួនឯងទេ»។

ការទ្វាជៈ ! ព្រះសម្ពុទ្ធត្រាស់តទៅ, ឆ្លើយរបស់អ្នកនេះមើលទៅឃើញថា ព្រាហ្មណ៍ទាំង អស់សុទ្ធតែជាជួរគោត្រមនុស្សខ្វាក់។ ព្រាហ្មណ៍ខ្វាក់ម្នាក់ ជឿពឹងផ្អែកទៅលើព្រាហ្មណ៍ខ្វាក់ម្នាក់ ទៀត ជឿខ្វាក់តៗគ្នារហូតមកឫសីជំនាន់ដើម ដែលជាអ្នកចងក្រង**វេទ** ក៏មិនបានឃើញឫសីជំនាន់ កណ្ដាល ក៏មិនបានឃើញដែរ ឫសីជំនាន់ក្រោយតៗមកទៀត ក៏រឹតតែមិនបានឃើញសោះទៅ ទៀត។ ដូច្នេះតថាគត យល់ឃើញថា ចម្លើយរបស់អ្នកនេះ ប្រាប់តថាគតច្បាស់ថាស្ថានភាព ព្រាហ្មណ៍ទាំងអស់ បើគន់គិតមើលឲ្យសព្វគ្រប់ ថាជួរគោត្រព្រាហ្មណ៍ខ្វាក់ ដូចជាជួរគោត្រ មនុស្សខ្វាក់រហូតទាំងគោត្រ យកជាការមិនបាន។ តទៅព្រះសម្ពុទ្ធត្រាស់ទេសនាទូន្មានព្រាហ្មណ៍ ទាំងនោះថា សេចក្ដីនេះមិនសមបើបុគ្គលជាអ្នកប្រាជ្ញប្រាកដដូចអ្នកគ្រប់គ្នាដែលជាអ្នកចេះដឹង ប្រសើរ នៅតែទទូចប្រកាន់ជឿថា "**មន្ត្រៈវេទ** ជាសច្ចឯកមិនមានពីរ ដទៃពីនេះសុទ្ធតែជា

---

១ - ឫសីពីបូរាណសុទ្ធតែអ្នកជំនាញ គឺឫសីអដ្ឋ, វាមកៈ, វាមទេវៈ, វេស្សាមិត្ត, យមតគ្គិ, អង្គីរស, ភារទ្វាជៈ, វាសេដ្ឋ, ភស្សបៈ, ភគុ។

ធម៌ខុស" ដូច្នេះឡើយ។

"**ភារទ្វាជៈ** ! ព្រះសម្ពុទ្ធត្រាស់ដណ្ដឹងតទៅទៀត, ចុះអ្នកគ្រប់គ្នាយល់ឃើញសេចក្ដីនេះ ថា ដូចម្ដេច? បើមិនដូច្នោះទេ មានតែជំនឿព្រាហ្មណ៍ដែលអ្នកអួតអាងមកនេះ ជា**អមូលិកាៈ** = មិនមានឫសគល់ពិតប្រាកដ មែនឬទេ?

«សូមទ្រង់ព្រះមេត្តាប្រោស ! កាបទិកព្រាហ្មណ៍ក្រាបបង្គំទូល, ជំនឿព្រាហ្មណ៍នេះ មិនមែនជាឥតហេតុផលទេ ពួកព្រាហ្មណ៍បានចូលទៅអង្គុយជិត បានសិក្សារៀនសូត្រ បានឮតៗគ្នាមក ហើយទើបប្រកាន់ជឿដូច្នេះឯង»។

«**ភារទ្វាជៈ** ! ព្រះសម្ពុទ្ធត្រាស់តទៅ, កាលពីមុន អ្នកបាននិយាយថា "មានជំនឿ" ឥឡូវនេះអ្នកនិយាយថា "បានឮតៗគ្នាមក បានជាមានជំនឿ"។

«**ភារទ្វាជៈ** ! ធម៌ ៥ប្រការគឺ ១-ជំនឿ = **សទ្ធា**, ២-ការគាប់ចិត្ត = **រុចិ**, ៣-ការឮតៗគ្នា = **អនុស្សវា**, ៤-ការត្រិះរិះនូវអាការ = **អាការបរិវិតក្កា**, ៥-ការចូលចិត្តតាមការយល់ឃើញ ការចូលចិត្តស៊ប់ = **ទិដ្ឋិនិជ្ឈានក្ខន្តិ** ទាំង ៥ប្រការនេះ តែងមានវិបាក ២ប្រការគឺ ៖

ក-ហេតុណា ដែលបុគ្គលស៊ប់, ដែលបុគ្គលគាប់ចិត្ត, ដែលបុគ្គលឮតៗតាមគ្នា, ដែលបុគ្គលត្រិះរិះនូវអាការ, ដែលបុគ្គលចូលចិត្តស៊ប់ តែហេតុនោះមិនមែនជាការពិត ក៏តែងមានដែរ

ខ-ហេតុណា ដែលបុគ្គលមិនជឿស៊ប់, ដែលបុគ្គលមិនគាប់ចិត្ត, ដែលបុគ្គលមិនឮតៗតាមគ្នា, ដែលមិនត្រិះរិះនូវអាការ, ដែលមិនចូលចិត្តស៊ប់ តែហេតុនេះ ជាការពិត ក៏តែងមានដែរ។

ដូច្នេះ ធម៌ ៥ប្រការនេះគឺ **សទ្ធា រុចិ អនុស្សវា អាការបរិវិតក្កា ទិដ្ឋិនិជ្ឈានក្ខន្តិ** មិនមែនជាពុទ្ធសាសនាទេ។ ពុទ្ធសាសនិកជន ត្រូវរៀបចំនូវធម៌ ៥ប្រការនេះ ដែលជាធម៌រារាំងមិនឲ្យយល់សេចក្ដីពិតបាន មិនត្រូវឲ្យធម៌នេះ ឋិតនៅក្នុងសន្តានចិត្តឡើយ។

លំដាប់នោះ ព្រះសម្ពុទ្ធត្រាស់ទេសនាទូន្មានថា : "ការស្វែងរកសច្ចធម៌មិនត្រូវសម្រេចសេចក្ដីអ្វីមួយដោយដាច់ខាតថា មានតែធម៌មួយនេះ **វេទ** ជាសច្ចឯក អ្វីដទៃទៀតសុទ្ធតែខុសទាំងអស់ ដូច្នេះឡើយ។

«សូមទ្រង់ព្រះមេត្តាប្រោស ! កាបទិបព្រាហ្មណ៍ក្រាបទូលសួរ, ដើម្បីស្វែងរកសច្ចធម៌ តើត្រូវ

ប្រើឧត្តមគតិដូចម្តេច?

**ការប្ងាជា:** ! ព្រះសម្ពុទ្ធត្រាស់ពន្យល់, មនុស្សម្នាក់ៗ តែងមានជំនឿ = **សទ្ធា** (Croyance, Foi)។ បើនិយាយ គេអាចនិយាយបានថា នេះជាជំនឿ = **សទ្ធា** របស់ខ្ញុំ ទៅទល់ពេលណាដែលគេរកសច្ចធម៌ឃើញ។ ប៉ុន្តែជំនឿនេះគេមិនត្រូវជម្រុលទៅដល់ការសម្រេចចិត្តដាច់ខាតថា នេះជាសច្ចឯក ឯធម៌ដទៃទៀតសុទ្ធតែខុសទាំងអស់ ដូច្នេះឡើយ"។ និយាយមួយបែបទៀតថា : "មនុស្សម្នាក់ៗអាចជឿអ្វីបានតាមដែលខ្លួនយល់ឃើញ ហើយអាចនិយាយបានថា ខ្ញុំជឿដូច្នេះទៅដល់ពេលណា ដែលខ្លួនរកសច្ចធម៌ឃើញ តែដោយជំនឿ (Croyance, Foi) នេះ គេមិនគប្បីសម្រេចដាច់ខាតថា អ្វីដែលខ្លួនជឿនោះជាសច្ចធម៌តែមួយ ឯធម៌ដទៃពីនេះ សុទ្ធតែខុសទាំងអស់ ដូច្នេះទេ"។

ព្រះសម្ពុទ្ធតែងត្រាស់ទេសនាទូន្មានថា : [១]

«មនុស្សតែងដេកត្រាំនៅក្នុង ថា ធម៌នេះប្រសើរបំផុតហើយគោរពសាស្តានោះ ទុកជាសាស្តាវិសេសបំផុតសាស្តាដទៃពីរបស់ខ្លួន សុទ្ធតែថោកទាប ទាំងអស់។ ដោយហេតុនេះបានជាមនុស្សចេះតែមានវិវាទមិនចេះចប់។

«មនុស្សបានឃើញអានិសង្សក្នុងខ្លួន ចំពោះអារម្មណ៍ដែលខ្លួនបានឃើញ បានឮ បានពាល់ត្រូវ ឬ ចំពោះសីលព្វត ក៏ប្រកាន់ខ្ជាប់នូវអានិសង្សនោះ ទុកជា **សក្កាយទិដ្ឋិ** = ឃើញថាជារបស់ខ្លួនប្រសើរ ហើយទុកគ្រូដទៃៗ ថាសុទ្ធតែថោកទាបទាំងអស់»។

«អ្នកដែលនៅក្នុងសំណាក់គ្រូណា ហើយដេកត្រាំនៅក្នុង គ្រូនោះតែងតែយល់ថា ធម៌គ្រូរបស់ខ្លួនប្រសើរបំផុត ធម៌គ្រូដទៃៗ សុទ្ធតែជាធម៌ថោកទាបទាំងអស់។ អ្នកប្រាជ្ញឈ្លាសវៃប្រដៅទុកថា : "ការជាប់ក្នុង នេះ ជាច្រវាក់ចង"។

ភិក្ខុទាំងឡាយ មិនគួរគប្បីជាប់ជំពាក់ចំពោះ និងសីលព្វតនេះឡើយ។

មួយទៀត ព្រះសម្ពុទ្ធត្រាស់ទេសនាបដិច្ចសមុប្បាទធម៌ [១] ចំពោះភិក្ខុទាំងឡាយ។ លុះបាន

---

១ - ខុទ្ទកនិកាយ សុត្តនិបាត បរដ្ឋមសូត្រ សៀវភៅទី៥៤ ទំព័រទី២៧៣។

១ - មជ្ឈិមនិកាយ មូលបណ្ណាសក មហាតណ្ហាសង្ខយសូត្រ សៀវភៅទី២២ ទំព័រ១៦៣។

*ស្តាប់ព្រះធម្មវិសេសទេសនាហើយ ភិក្ខុទាំងឡាយក្រាបបង្គំទូលព្រះសម្ពុទ្ធថា ?*

*«សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គបានឃើញធម៌នោះហើយ»។*

*«ភិក្ខុទាំងឡាយ ! ព្រះសម្ពុទ្ធត្រាស់បញ្ជាក់, បើអ្នករាល់គ្នាជាប់ជំពាក់ រីករាយ កួចកាន់ រាប់អានចំពោះនេះថា : បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយតណ្ហានិងនៅឡើយទេ ម្ដេចឡើយអ្នកនឹងបានយល់ច្បាស់នូវធម៌ដែលមានឧបមាដូចជា សំពៅកេត្រាដែលតថាគតសម្ដែងហើយដើម្បីប្រយោជន៍រើខ្លួនឲ្យចាក* **ឱឃៈ** *ទាំង៤ មិនមែនដើម្បីប្រយោជន៍ឲ្យប្រកាន់នូវខន្ធបញ្ចកៈនោះទេ មិនដូច្នោះឬ។*

*ក្នុងពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់តែងតែត្រាស់ទេសនា ប្រៀបធៀបធម៌ព្រះអង្គថា ដូចជាសំពៅកេត្រា សម្រាប់ជិះឆ្លងទៅកាន់ត្រើយនាយ មិនមែនសម្រាប់ប្រកាន់ខ្ជាប់ ហើយលីសែងយកទៅតាមទេទ្រង់ត្រាស់ថា :*

*«ភិក្ខុទាំងឡាយ ? មនុស្សម្នាក់ ជាអ្នកធ្វើដំណើរ ដើរទៅដល់ត្រើយសមុទ្រត្រើយអាយប្រកបដោយភ័យច្រើន ត្រើយនាយជាត្រើយនិរភ័យ ប្រកបដោយក្ដីក្សេមក្សាន្ត តែមិនមានអ្វីនឹងឆ្លងទៅ។ មនុស្សនេះគិតថា សមុទ្រនេះធំធេងណាស់ ត្រើយអាយនេះមានភ័យច្រើនណាស់ ត្រើយនាយឥតភ័យ មានតែក្ដីក្សេមក្សាន្ត តែមិនមានយានឆ្លងទៅ ទូកក៏មិនមាន ! ជាការគាប់ប្រសើរណាស់ ប្រសិនបើអាត្មាអញយកស្មៅ ឈើ មែកឈើ ឬ ស្លឹកឈើ មកធ្វើជាក្បូន ហើយអាស្រ័យដោយក្បូននេះ អាត្មាអញនឹងឆ្លងទៅត្រើយនាយ ដោយប្រើដៃនិងជើងអុំទូកចែវទៅ។*

*ភិក្ខុទាំងឡាយ ? មនុស្សអ្នកធ្វើដំណើរនេះ ដើររកស្មៅ ឈើ មែកឈើ សន្លឹកឈើ រកបានហើយ ធ្វើជាក្បូននេះ អាស្រ័យដោយក្បូននេះគេឆ្លងទៅត្រើយនាយ ដោយប្រើដៃនិងជើងអុំទូកចែវទៅ។ ឆ្លងទៅដល់ត្រើយនាយហើយមានប្រស្នាមួយចោទឡើង អ្នកធ្វើដំណើរនេះគិតថា អាត្មាអញធ្វើដូម្ដេចអេះ? ក្បូននេះ ជួនអាត្មាអញបានសម្រេចដូចបំណង ហើយអាស្រ័យដោយក្បូនជាពំនឹងនេះ អាត្មាអញបានដល់ត្រើយ ប្រកបដោយក្ដីក្សេមក្សាន្ត ដើម្បីតបឧបការៈ គួរតែអាត្មាអញលើកក្បូនជាពំនឹងដ៏ប្រសើរនេះដាក់លើក្បាលហើយទូល ឬ អាត្មាអញលើកក្បូននេះ ដាក់លើស្មាហើយលីយកទៅទើបសម។*

ភិក្ខុទាំងឡាយ សេចក្តីនេះ អ្នកទាំងឡាយគិតដូចម្តេច? អ្នកដំណើរយើងនេះ ត្រូវធ្វើតាមគំនិតដែលខ្លួនគិតឃើញនេះ ឬ ទើបឈ្មោះថាធ្វើការគួរសមចំពោះក្បូននោះ?

សូមទ្រង់ព្រះមេត្តាប្រោស ! ពុំគួរសមទេ

ព្រះសម្ពុទ្ធទ្រង់បន្តព្រះពុទ្ធដីកាតទៅទៀតថា :

«ភិក្ខុទាំងឡាយ ! ឥឡូវនេះ អ្នកធ្វើដំណើរយើងបានឆ្លងមកដល់ត្រើយនាយដោយក្តីក្សេមក្សាន្តហើយ ឧបមាថា អ្នកធ្វើដំណើរនេះគិតថា "ក្បូននេះមានគុណបំណាច់នឹងអាត្មាអញណាស់ អាស្រ័យដោយក្បូននេះអាត្មាអញបានឆ្លងមកដល់ត្រើយ ប្រកបដោយក្តីក្សេមក្សាន្តហើយ គួរណាស់តែអាត្មាអញលើកក្បូននេះ ដាក់ទៅលើត្រើយ ឬ ចងទុក ឬ ក៏ពន្លិចចោលទៅ ហើយធ្វើដំណើរចរចេញទៅតាមក្តីប្រាថ្នា។ ធ្វើដូច្នេះទើបឈ្មោះថាអ្នកធ្វើដំណើរនេះ ចេះធ្វើការគួរសមចំពោះក្បូននោះ។

ភិក្ខុទាំងឡាយ ! ធម្មវិន័យដែលតថាគតបានសម្តែងហើយ ប្រៀបដូចក្បូនដូច្នោះដែរធម្មវិន័យនេះ គ្រាន់តែជាសំពៅកេត្រាសម្រាប់ជិះឆ្លងតែប៉ុណ្ណោះទេ មិនមែននាំឲ្យកើតមានឧបាទានសម្រាប់ប្រកាន់ខ្ជាប់ទេ។

ភិក្ខុទាំងឡាយ ! បុគ្គលណាមួយយល់ឃើញធម្មវិន័យនេះ ថាទុកដូចជាសំពៅកេត្រា បុគ្គលនោះឈ្មោះថាបានប្រតិបត្តិធម្មវិន័យ ដែលតថាគតសម្តែងហើយនេះសមគួរទៅតាមធម៌ហើយ ព្រោះបានលះបង់ធម៌ ធម៌[១] ទាំងអស់ចោលបង់អស់ហើយ។

ដំណើរនិទាននេះ ធ្វើឲ្យយើងបានយល់ច្បាស់ថា **ពុទ្ធវចនៈ** មានអត្ថន័យថានាំសត្វទៅកាន់ **សិវហានសន្តិវរបទ បរមសុខ ខេមឋាន** ត្រើយត្រានអមតនិព្វានពិតប្រាកដ។ ពុទ្ធវចនៈនេះជា**ស្វាក្ខាតធម៌**ដឹកនាំសត្វទៅកាន់ទីបំផុតទុក្ខបានពិត។ **ពុទ្ធវចន** នេះជា **និយ្យានិកធម៌** គឺជាសំពៅកេត្រាដឹកនាំសត្វទៅកាន់ត្រើយត្រានអមតនិព្វានពិតប្រាកដ។ ព្រះសម្ពុទ្ធទ្រង់មិនសម្តែងធម៌ទុកគ្រាន់តែសម្រាប់បង្អួតសត្វលោក ឬ ទុកគ្រាន់តែបង្ហាញបុគ្គលបញ្ញវន្តឲ្យចង់មើល

---

១ - ក្នុងអដ្ឋកថាសូត្រនេះពន្យល់ថា កុសលធម៌ក្តី អកុសលធម៌ក្តី ព្រមទាំងឈានសមាបត្តិ ត្រូវលះបង់ចោលទាំងអស់ ព្រោះធម៌ទាំងអស់នេះ មិននាំឲ្យទៅដល់ទីបំផុតទុក្ខទេ។

ចង់ដឹងនោះទេ។ ធម្មវិន័យព្រះអង្គ ពិតជាធម៌នាំសន្តិភាព នាំសេចក្តីសុខ មកប្រគល់ឲ្យសត្វលោក ដែលកំពុងក្តៅរោលរាលដោយភ្លើងទុក្ខ ភ្លើងកិលេសបានយ៉ាងសក្តិសិទ្ធិបំផុត។ ធម្មវិន័យព្រះអង្គនេះជាទឹកអម្រឹត គួរសាធុជនក្រេបផឹកបំបាត់ក្តីស្រេកឃ្លានបានយ៉ាងប្រសើរបំផុត។

អ្នកមិនបានសិក្សាពុទ្ធសាសនា ដោយម៉ត់ចត់តែងនិយាយថា ពុទ្ធសាសនាមិនមានលក្ខណៈដោយបរិបូណ៌ទៅតាមផ្លូវលោក គឺគេចង់និយាយថា ព្រះសម្ពុទ្ធមិនចេះវិជ្ជាផ្លូវលោក សម្រាប់បង្កើតសារពើវត្ថុជាផាសុក = Confort សម្រាប់មនុស្សលោកឡើយ។ ព្រះសម្ពុទ្ធទ្រង់ជាសព្វញ្ញុពុទ្ធ ទ្រង់មិនមានអ្វីនៅសល់ទើសទាក់នឹងព្រះបញ្ញាញាណព្រះអង្គទេ ធម៌ណាជាកុសលជាធម៌ដឹកនាំសត្វលោកទៅកាន់ សន្តិវរបទ ទ្រង់តែងតែសម្តែងធម៌នោះអស់ចិរៈវេលា ៤៥វស្សា ដើម្បីជាប្រយោជន៍ដល់មនុស្សលោក ទេវលោកព្រហ្មលោក។ ធម្មវិន័យព្រះអង្គនេះជាកញ្ចក់សម្រាប់ឆ្លុះមើលអ្វីក៏បាន មើលល្អក៏បានមើលអាក្រក់ក៏បាន ស្រេចហើយតែអ្នកឆ្លុះត្រូវការ។

សម័យមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថនៅសីលបាវន ជិតក្រុង **កោសម្ពី**។ ពេលនោះ ទ្រង់ឈោងព្រះហស្តទៅចាប់សន្ទឹកឈើមួយក្តាប់មកទុកក្នុងព្រះហស្ត ហើយទ្រង់ត្រាស់សួរទៅកាន់ភិក្ខុទាំងឡាយថា :[១]

«ភិក្ខុទាំងឡាយ ! អ្នកទាំងឡាយយល់ឃើញដូចម្តេច? សន្ទឹកឈើមួយក្តាប់ ដែលនៅក្នុងដៃតថាគតនេះ និងសន្ទឹកឈើដែលមាននៅឰដ៏ដើមឈើឯណោះ ឯណាច្រើនជាងឯណា?

សូមទ្រង់ព្រះមេត្តាប្រោស ! ភិក្ខុទាំងឡាយ ទូលពុទ្ធដីកា ហើយក្រាបទូលថា សន្ទឹកឈើដែលនៅក្នុងក្តាប់ព្រះហស្តនេះ មានចំនួនតិចណាស់ ឯសន្ទឹកដែលមាននៅឰដ៏ដើមឈើក្នុងសីសបាវននេះ មានចំនួនច្រើនណាស់ និងគណនាត្រារាប់ពុំបានឡើយ។

ភិក្ខុទាំងឡាយ ធម្មវិន័យដែលតថាគតបានត្រាស់ដឹង ហើយដែលតថាគតយកមកសម្តែងប្រាប់ដល់អ្នកទាំងឡាយ មានចំនួនតិចណាស់ ឯធម៌ដែលតថាគត បានត្រាស់ដឹងហើយមិនបានយកមកសម្តែងប្រាប់ដល់អ្នកទាំងឡាយ មានច្រើនណាស់ ដូចសន្ទឹកឈើដែលមាននៅក្នុងសីសបាវននេះឯង។ ចុះហេតុអ្វី ក៏តថាគតមិនយកធម៌ទាំងអស់នោះមកសម្តែងប្រាប់អ្នកទាំង

---

១ - សំយុត្តនិកាយ មហាវារវគ្គ សីសបាបណ្ណវគ្គ សៀវភៅទី៣៩ ទំព័រ២៧៣។

ឡាយ? ព្រោះថាធម៌ទាំងអស់នោះមិនមានប្រយោជន៍មិននាំសត្វលោកទៅនិព្វាន។

??????????????????????????????????????????????????

៦. ជីវិតផ្សេង សរីរផ្សេង = **អញ្ញំ ជីវំ អញ្ញំ សរីរំ**

៧. សត្វស្លាប់ហើយ កើតទៀត = **ហោតិ តថាគតោ បរម្មរណា**

៨. សត្វស្លាប់ហើយ មិនកើតទៀត = **ន ហោតិ តថាគតោ បរម្មរណា**

៩. សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន = **ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា**

១០.សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន = **នេវ ហោតិ ន ចហោតិ តថាគតោ បរម្មរណា**

ប្រស្នាទាំងនេះ ព្រះសម្ពុទ្ធមិនទាន់បានសម្ដែងដល់អាត្មាអញទេ បើដូច្នោះគួរតែអាត្មាអញចូលទៅក្រាបបង្គំទូលសួរ ចំពោះព្រះភក្ត្រព្រះអង្គ បើទ្រង់មិនព្រមសម្ដែងដល់អាត្មាអញទេ អាត្មាអញលែងបួស លែងប្រព្រឹត្តព្រហ្មចរិយាធម៌ក្នុងសំណាក់ព្រះអង្គ ហើយលាសិក្ខាបទត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ"។

ថ្ងៃមួយតមក **មាលុង្ក្យបុត្ត** ចូលទៅក្រាបបង្គំគាល់សួរប្រស្នានេះតាមដែលខ្លួនបានគិតទុកមុន។ ទ្រង់ព្រះសណ្ដាប់ហើយ ព្រះសម្ពុទ្ធត្រាស់តបថា : "តថាគតមិនបានហៅអ្នកឲ្យចូលមកបួសហើយធ្វើកត្តិកាថានឹងសម្ដែងធម៌នេះប្រាប់ដល់អ្នកទេ ចុះអ្នកមកអុកជាទុក្ខប្រាប់តថាគតធ្វើអ្វី ? ទ្រង់ត្រាស់តទៅថា :

«**មាលុង្ក្យបុត្ត** ! បើមានអ្នកណាម្នាក់មកនិយាយប្រាប់តថាគតថា ខ្ញុំព្រះអង្គមិនទាន់បួសប្រព្រឹត្តព្រហ្មចរិយាធម៌ក្នុងសំណាក់ព្រះអង្គទេ បើទ្រង់ព្រះករុណាមិនទាន់បានសម្ដែងប្រទានខ្ញុំព្រះអង្គថា "លោកទៀង"។ល។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន» ដូច្នេះ អ្នកនោះមុខជាស្លាប់អសារបង់សៀតមុនតថាគតសម្ដែងប្រាប់មិនខាន ប្រៀបដូចបុរសត្រូវសរ ហើយនិយាយប្រាប់គ្រូពេទ្យថា ខ្ញុំមិនទាន់ឲ្យវះដកយកសរនេះទេ ចាំខ្ញុំបានដឹងថា :

- អ្នកណាជាអ្នកបាញ់សរនោះ ជាក្សត្រ ឬជាព្រាហ្មណ៍ ជាវេស្ស ឬជាសុទ្ទ មនុស្សទាប ឬ

ខ្ពស់ ស ឬខ្មៅ ពណ៌សណ្តែកបាយ ឬប្រផេះ នៅស្រុកនិគមណាសិន,

- អាវុធនោះ ជាកាំភ្លើង ឬធ្នូស្នា ខ្សែធ្នូនេះ ជាសម្បកពាក់ ពន្ទុំឬស្សី សសៃសត្វ សម្បកខ្ទើង ពីរ ឬវល្លិទឹកដោះសិន,

- សរដែលមុតនោះ ជាព្រៃឈើ ឈើស្រុក, ជាសរសៀតដោយស្លាបសត្វត្មាត ប្រមង់ ខ្វែង ក្អែក ឬទុងសិន,

- សរនេះរុំដោយសរសៃកន្ទុយគោ ក្របី សីហខ្មៅ ឬស្វាសិន,

- សរនេះ មានមុខមូល មុខសំប៉ែត មានធ្មេង មុខស្រោបដែក មុខដូចពន្លាក ឬសរធ្វើពីជាង ទ្រាំងសិន សឹមខ្ញុំព្រមឲ្យដកយកសរនេះចេញពីកាយខ្ញុំ។

**មាលុង្ក្យបុត្រ** ! បុរសត្រូវសរនោះ នៅរង់ចាំដឹងមុនមិនទាន់ទេនឹងត្រូវស្លាប់មុន ឥត ប្រយោជន៍អសារបង់ពុំខានឡើយ។

**មាលុង្ក្យបុត្រ** ! បើចាំដឹងថា "លោកទៀង ។ល។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិន កើតទៀតក៏មិនមែន" សិន សឹមប្រព្រឹត្តព្រហ្មចរិយាធម៌ = (**ព្រហ្មចរិយវាស**) ក្រោយបើគេនៅតែ មិនទាន់ដឹងមុនទេ ក៏ឥត "ប្រយោជន៍" ដែរ ព្រោះធម៌ជាសឹកសត្រូវដូច **ជា ជរា ព្យាធិ មរណៈ សោក បរិទេវ ទុក្ខ ទោមនស្ស ឧបាយាស** ចេះតែបៀតបៀនសត្វជានិច្ច ជាធម៌ដែល តថាគតបញ្ញត្តិថា "មានសេចក្តីវិនាសពិត" ក្នុងបច្ចុប្បន្នកាលនេះ។

**មាលុង្ក្យបុត្ត** ! ការប្រព្រឹត្តិព្រហ្មចរិយាធម៌ មិនមែនពឹងផ្អែកទៅលើ (Dogme) ដូចបាន ពោលមកទាំងអស់នេះទេ ការដែលត្រូវធ្វើភ្លាមៗ គឺប្រស្នាបន្ទាន់ដែលកំពុងដុតសត្វលោកទូទៅឲ្យ ឆេះរោលរាលស្ទន់ស្ទោអន្ទះសានោះគឺ **ជាតិ ជរា ព្យាធិ មរណា សោកបរិទេវ ទុក្ខទោមនស្ស ឧបាយាស** ព្រមទាំងធម៌ "ទីបំផុតទុក្ខ" ទាំងអស់នេះសុទ្ធតែជាប្រស្នាបន្ទាន់ ត្រូវធ្វើភ្លាមៗ បង្អង់ទុកយូរតទៅទៀតពុំបានឡើយ។

**មាលុង្ក្យបុត្ត** ! ចូរអ្នកចាំទុកក្នុងចិត្តចុះថា "នេះជាធម៌ដែលតថាគតត្រូវសម្តែង ដូច តថាគតបានសម្តែងរួចមកហើយ, នេះជាធម៌ដែលតថាគតមិនសម្តែង ដូចតថាគតមិនសម្តែង ហើយ។ ឯធម៌ដែលតថាគតមិនសម្តែងនេះគឺ លោកទៀង។ល។ សត្វស្លាប់ហើយ កើតទៀតក៏មិន

មែន មិនកើតទៀតក៏មិនមែន។ ហេតុអ្វីក៏តថាគតមិនសម្តែងការយល់ឃើញ = ( ) នោះ?

**មាលុង្ក្យបុត្ត** ! បានជាតថាគតមិនសម្តែង ព្រោះនេះមិនមានប្រយោជន៍ មិនមែនជាការចាំបាច់ មិនមែនជាខាងដើមនៃព្រហ្មចរិយាធម៌ មិនមែននាំឲ្យកើតក្តីនឿយណាយការប្រាសចាករាគៈ ការរំលត់ទុក្ខការស្ងប់ ការដឹងច្បាស់ ការត្រាស់ដឹង និព្វានឡើយ។

អ្វីដែលតថាគតសម្តែង ?

**មាលុង្ក្យបុត្ត** ! តថាគតតែងសម្តែងថា "នេះទុក្ខ នេះហេតុនាំឲ្យកើតទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះ**បដិបទា**ជាផ្លូវនាំទៅកាន់ការរំលត់ទុក្ខ"។

ហេតុអ្វីក៏តថាគតសម្តែងធម៌នេះ?

**មាលុង្ក្យបុត្ត** ! ព្រោះថាធម៌នេះ មានប្រយោជន៍ [១] សំខាន់ណាស់ ចាំបាច់ណាស់ ជាខាងដើមនៃ **ព្រហ្មចរិយាធម៌** នាំឲ្យកើតក្តីនឿយណាយ ប្រាសចាករាគរំលត់ទុក្ខ ស្ងប់ ដឹងច្បាស់ ត្រាស់ដឹង និព្វាន"។

សេចក្តីនេះ នាំឲ្យយើងយល់ច្បាស់ថា ពុទ្ធសាសនា ជាសាសនារំដោះទុក្ខ រំដោះទុក្ខយ៉ាងអស់ជើង ដែលមិនធ្លាប់មានមកក្នុងប្រវត្តិសាស្ត្រសាសនានៃសកលលោកឡើយ។ ពុទ្ធសាសនាមានទឹកទម្ងន់ទៅខាងលោកុត្តរធម៌។

មួយទៀត ប្រស្នាយើងដដែលនេះ [២] មានចោទឡើងច្រើនណាស់ក្នុងសម័យពុទ្ធកាល ប្រស្នានេះក៏ចោទខ្លាំងណាស់ ព្រោះសម័យនេះជាសម័យភ្ញាក់រលឹក។ មាន**បរិព្វាជក**ម្នាក់ មានការជឿងធ្ងល់ចំពោះ (Dogme) ដូចយើងបានជជែកគ្នាមកហើយនេះដែរ។ សម័យមួយអង្គព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថនៅក្នុងវត្ត **ជេតវនារាម** ជាអារាមអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយជិតក្រុង **សាវត្ថី** កាលនោះមាន **បរិព្វាជក** ម្នាក់ឈ្មោះ **វច្ឆគោត្រ** ចូលទៅក្រាបបង្គំគាល់ព្រះអង្គ ហើយលើកយកប្រស្នាដដែលនេះ មកក្រាបទូលសួរព្រះអង្គថា :

---

១ - កស្មា ចតំ មាលុង្ក្យបុត្ត មយា ព្យាកតំ ឯតញ្ហិ មាលុង្ក្យបុត្ត អត្ថសញ្ហិតំ ឯតំ អាទិ ព្រហ្មចរិយំ ឯតំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ តស្មា តំ មយា ព្យាកតំ។

២ - មជ្ឈមនិកាយ មជ្ឈិមបណ្ណាសក អគ្គិវច្ឆសូត្រ សៀវភៅទី២៤ ទំព័រ៨។

«សូមទ្រង់ព្រះមេត្តាប្រោស ! ចុះព្រះអង្គមានការយល់ឃើញ = (Dogme) ថាលោកទៀង—លោកមិនទៀង—លោកមានទីបំផុត លោកមិនមានទីបំផុត-ជីវិតគឺសរីរ-ជីវិតផ្សេង សរីរផ្សេង-សត្វស្លាប់ហើយ កើតទៀត-សត្វស្លាប់ហើយ មិនកើតទៀត-សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន-សត្វស្លាប់ហើយ កើតទៀតក៏មិនមាន មិនកើតទៀតក៏មិនមាន នេះសេចក្ដីពិត ដទៃពីនេះ សុទ្ធតែជាមោឃៈទាំងអស់ ដូច្នេះឬ?

«ទេ ទេ វច្ឆ ! ព្រះសម្ពុទ្ធតប តថាគតមិនមានការយល់ឃើញ ដូច្នេះទេ»។

«សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជកវច្ឆគោត្រ ក្រាបទូលសួរដេញទៀត កាលខ្ញុំព្រះអង្គក្រាបទូលសួរខាងលើនេះ ព្រះមានបុណ្យតបថា ទ្រង់មិនមានការយល់ឃើញ = យ៉ាងនេះទេ បើដូច្នេះតើព្រះមានបុណ្យមានការយល់ឃើញថា មានទោសដូចម្ដេចខ្លះ?

«វច្ឆ ! ព្រះសម្ពុទ្ធតបតទៅ តថាគតបានត្រាស់ដឹងថា [១] ធម៌ទាំងនេះជា សាំញាំ ជាវង្វេង ជាបះបើក ជាឃ្វេងឃ្វាង ជានាំសត្វឲ្យលិចទៅក្នុងអន្ទង់ទុក្ខ រងទុក្ខ លំបាក ចង្អៀតចង្អល់ ក្ដៅពេលពាល មិននាំឲ្យនឿយណាយ ប្រាសចាកពាគ រលត់ស្ងប់ ដឹងច្បាស់ ត្រាស់ដឹង និព្វាន ឡើយ»។ តថាគតឃើញទោសនេះហើយ បានជាតថាគតមិនមានការយល់ឃើញ = (Dogme) នោះឯង។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជកវច្ឆគោត្រក្រាបទូលសួរដេញតទៅទៀត ចុះព្រះមានបុណ្យ មានការយល់ឃើញ = នេះបន្តិចបន្តួចខ្លះដែរឬទេ?

មិនមានទេ វច្ឆ ! ព្រះសម្ពុទ្ធត្រាស់តទៅទៀត តថាគតបានលះបង់ការយល់ឃើញ = នេះចោលអស់ហើយ ព្រោះតថាគតបានត្រាស់ថា : "រូបដូច្នេះ ហេតុដែលនាំឲ្យកើតរូបដូច្នេះ ហេតុដែលនាំឲ្យរលត់រូបដូច្នេះ វេទនាដូច្នេះ ហេតុដែលនាំឲ្យកើតវេទនាដូច្នេះសញ្ញាដូច្នេះ ហេតុដែលនាំឲ្យកើតសញ្ញាដូច្នេះ ហេតុដែលនាំឲ្យរលត់សញ្ញាដូច្នេះសង្ខារដូច្នេះ ហេតុដែលនាំឲ្យកើតសង្ខារដូច្នេះ ហេតុដែលនាំឲ្យរលត់សង្ខារដូច្នេះ វិញ្ញាណដូច្នេះ ហេតុដែលនាំឲ្យកើតវិញ្ញាណដូច្នេះ ហេតុដែលនាំឲ្យរលត់វិញ្ញាណដូច្នេះ» ព្រោះហេតុនោះ បានជាតថាគតពោលថា : តថាគតរួច

---

១ - ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ សទុក្ខំ សវិឃាតំ សឧបាយាសំ សបរិឡាហំ ន និព្វិទាយ ន វិរាគាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ។

ស្រឡះហើយ ព្រោះមិនប្រកាន់មាំ ព្រោះអស់ទៅ ព្រោះប្រាសចាកពាគ ព្រោះរលត់ទៅ ព្រោះលះបង់ ព្រោះរលាស់ចោលចេញនូវសេចក្តីមើងងាយទាំងពួង នូវសេចក្តីបន្ទោកបន្ទាបទាំងពួង និងអហង្ការមមង្ការ អនុស័យ [១] ទាំងពួង។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្វាជកវច្ឆគោត្រ ត្រាស់សួរសេចក្តីផ្សេងមួយទៀត, ចុះភិក្ខុដែលចិត្តរួចស្រឡះហើយ **វិមុត្តិចិត្ត** តើទៅកើតឯណាទៀតដែរឬទេ?

«**វច្ឆ** ! ទ្រង់ត្រាស់តប, បើនិយាយថា : កើតទៀត ក៏មិនគួរ។

សូមទ្រង់ព្រះមេត្តាប្រោស ! **បរិញ្វាជកវច្ឆគោត្រ** ក្រាបទូលសួរទៀត, បើដូច្នោះ មានតែមិនកើតទៀតឬ?

ទេ **វច្ឆ** ! ទ្រង់ត្រាស់តប, បើនិយាយថា : មិនកើតទៀត ក៏មិនគួរដែរ។

សូមទ្រង់ព្រះមេត្តាប្រោស ! **បរិញ្វាជកវច្ឆគោត្រ** ក្រាបទូលបន្ថែមទៀតបើដូច្នោះ មានតែកើតទៀតខ្លះ មិនកើតទៀតខ្លះឬ?

ទេ **វច្ឆ** ! ទ្រង់ត្រាស់តបបន្ថែម, បើនិយាយថា : កើតទៀតខ្លះ មិនកើតទៀតខ្លះ ដូច្នេះ ក៏មិនគួរដែរ។

សូមទ្រង់ព្រះមេត្តាប្រោស ! **បរិញ្វាជកវច្ឆគោត្រ** ក្រាបទូលសួរបញ្ជាក់ទៀត, បើដូច្នោះ មានតែ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះឬ?

ទេទេ វច្ឆ ! ទ្រង់ត្រាស់បញ្ជាក់, និយាយថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏នៅតែមិនគួរដែរ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្វាជកវច្ឆគោត្រ ទុញទាល់គំនិតក្រាបទូលដោយត្រង់ថា : ខ្ញុំព្រះអង្គមិនយល់ទាល់តែសោះ ខ្ញុំព្រះអង្គជាមនុស្សវង្វេងវង្វាងអស់ទៅហើយ។

«អើ **វច្ឆ** ! ព្រះ**ពិជិតមារ**ត្រាស់បណ្តោយតាមអ្នកមិនគួរយល់មែន អ្នកជាមនុស្សវង្វេងវង្វាងមែន ព្រោះថា ធម៌នេះជ្រាលជ្រៅអ្នកឃើញបានដោយកម្ម ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់ ជាធម៌ថ្លៃថ្លា ប្រើការត្រិះរិះ វិតក្កៈ មិនចុះ ជាធម៌ល្អិតសុខុម មានតែអ្នកប្រាជ្ញទើបដឹងបាន។

---

១ - បានដល់ ទិដ្ឋិ តណ្ហា មានៈ ទាំង៣ ប្រការនេះ។

វច្ឆ អើយ ! ទ្រង់ត្រាស់តទៅទៀត, ធម៌នេះ ខ្លួនអ្នកមានការយល់ឃើញ = (Dogme) ដទៃ មានការពេញចិត្តដទៃ មានការគាប់ចិត្តដទៃ មានអាចារ្យដទៃ តែងដឹងបានដោយកម្រណាស់។

នែ វច្ឆ ! ទ្រង់ត្រឡប់សួរទៅវិញ, បើមានភ្លើងកំពុងឆេះនៅមុខអ្នក អ្នកក៏បានដឹងថា មានភ្លើងកំពុងឆេះនៅមុខអាត្មាអញដែរ បើមានគេសួរអ្នកថា ភ្លើងដែលកំពុងតែឆេះនៅក្នុងទីចំពោះមុខអ្នកនេះ អាស្រ័យដោយអ្វី?

សូមទ្រង់ព្រះមេត្តាប្រោស ! **បរិព្វាជកវច្ឆគោត្រ** ក្រាបទូល, បើមានគេសួរខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងឆ្លើយថា ភ្លើងដែលឆេះនេះ អាស្រ័យដោយស្មៅនិងអង្កត់ឧស។

អើ វច្ឆ ! ទ្រង់ដេញសួរតទៅ, ចុះបើភ្លើងនេះ រលត់ទៅវិញនៅក្នុងទីចំពោះមុខអ្នក ហើយមានគេសួរអ្នកថា ភ្លើងដែលរលត់ទៅក្នុងទីចំពោះមុខអ្នកនេះ ទៅណា? ទៅខាងកើត ឬ ខាងលិច? ទៅខាងត្បូង ឬ ខាងជើង? បើគេសួរយ៉ាងនេះ តើអ្នកដោះស្រាយថាដូចម្ដេច?

សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជកវច្ឆគោត្រ ក្រាបទូលដោយត្រង់ខ្ញុំព្រះអង្គក៏ទាល់គំនិតនិងដោះស្រាយដែរ និងឆ្លើយដូចម្ដេចក៏មិនត្រូវ ព្រោះមើលទៅឃើញ ស្មៅនិងអង្កត់ឧសឆេះអស់ទៅហើយ នៅសល់តែកំញម ឯភ្លើងរលត់បាត់អស់ទៅហើយ មើលមិនឃើញថាទៅឯណាទេ។

អើ វច្ឆ អើយ ! ទ្រង់ត្រាស់ពន្យល់តទៅទៀត, កាលបុគ្គលបញ្ញត្តិវសត្វបញ្ញត្តិដោយរូប **វេទនា សញ្ញា សង្ខារ វិញ្ញាណ**។ **រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ** ជា **ខន្ធបញ្ចកៈ** នេះ តថាគតលះបង់ចោលអស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក លែងកើតមានជា **រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ** ទៀតហើយ មិនកើតជាធម្មតា។ តថាគតរួចស្រឡះ ចាកចំណែកនៃ **រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ** នេះអស់ហើយ ជាអ្នកជ្រៅដោយគុណ ដែលបុគ្គលប្រមាណមិនបាន ស្ទង់បានដោយកម្រដូចសមុទ្រ នឹងថា កើតទៀតក៏មិនគួរ មិនកើតទៀតក៏មិនគួរ កើតខ្លះមិនកើតខ្លះ ក៏មិនគួរ កើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏មិនគួរដែរ។

ទីបំផុត **ធម្មីកថា** បរិព្វាជកវច្ឆគោត្រ ក្រាបទៀបបាទាអង្គ ព្រះសម្ពុទ្ធហើយពោលសរសើរពុទ្ធគុណថា :

«បពិត្រព្រះ**គោតម**ដ៏ចម្រើន ! មហាសាលព្រឹក្សដុះនៅជិតគ្រាមក្តីដុះជិតនិគមក្តី ប្រកប

*ដោយសាខាដ៏ហើយដោយស្មោមស្មឹកទ្រូឈឹងទ្រូឈៃសាខា ដ៏ហើយដោយស្មោមស្មឹកនោះ វិនាស អន្តរាយទៅដោយ***អនិច្ចតាធម៌*** សំបកនិងក្រមរទាំងឡាយ វិនាសអស់ទៅស្រាយវិនាសអស់ទៅ នៅសល់តែខ្លឹមសុទ្ធយ៉ាងណាមិញ ធម្មវិន័យព្រះអង្គនេះ បរិសុទ្ធផូរផង់អស់មែកសាខា ស្មោមស្មឹក សំបក ក្រមរស្រាយរលីង នៅសល់តែខ្លឹមសុទ្ធ យ៉ាងនោះឯង»។*

*សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជកវច្ឆគោត្រ ថ្វាថ្ងៃងតទៅទៀត, ពុទ្ធដីកានេះ ពីរោះណាស់ !* ***ស្វាក្ខាតធម៌*** *នេះ ដូចជាគេផ្ងារនូវវត្ថុដែលគេផ្កាប់ ឬបើកនូវគម្របដែលគេគ្រប ឬក៏ដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះសោតដូចគេដុតប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា អ្នកមានភ្នែកភ្លឺ នឹងបានឃើញរូបទាំងឡាយយ៉ាងច្បាស់។*